# មជ្ឈមណ្ឌលឯកសារកម្ពុជា

## បទសម្ភាសន៍ជាមួយឈ្មោះ ងឹម នឿន ភេទប្រុស អាយុ៥២ឆ្នាំ
## ភូមិត្រពាំងឈូក ឃុំត្រពាំងធំខាងត្បូង ស្រុកត្រាំកក់ ខេត្តតាកែវ
## ថ្ងៃទី២០ ខែមករា ឆ្នាំ២០១១
## សម្ភាសដោយៈ វ៉ាន់ថាន់ ពៅដារ៉ា និង ឡុង ដានី

នឿន ៖ ចង់សាកសួរពីប្រវត្តិមានគោលបំណងអីដោយមានគ្រោះថ្នាក់ លោកគ្រូ?

ដានី ៖ បាទ! អត់មានគ្រោះថ្នាក់ ពីព្រោះពួកខ្ញុំពួកអ្នកប្រវត្តិសាស្រ្ត ។

នឿន ៖ ចេះតែឆ្ងល់ប្រជាជន ។

ដានី ៖ ពីព្រោះពួកខ្ញុំជាអ្នកប្រវត្តិសាស្រ្ត យើងបានព័ត៌មានទៅ យើងសរសេរ យើងចងក្រងទុកសម្រាប់ឲ្យក្មេងៗជំនាន់ក្រោយ ឬក៏អ្នកសិក្សាស្រាវជ្រាវ ដូចជាបោះពុម្ពសៀវភៅនេះ យើងមើលជាទូទៅ យើងចែកជាទូទៅ យើងផ្សព្វផ្សាយ អ្នកណាក៏អាចមើលបាន កូនសិស្សប្រជាជន អ្នកធ្វើការគ្រប់ផ្នែក យើងអាចមើលសៀវភៅនេះបានទាំងអស់ ។

នឿន ៖ គោលបំណងរបស់លោកគ្រូ ជាដំបូងចង់សាកសួរពីជីវិតរបស់ខ្ញុំតាំងពីមុនមក?

ដានី ៖ បាទ! សំខាន់ជីវិតរបស់លោកពូ ហើយនឹងដូចថានៅក្នុងស្រុកភូមិយើងយ៉ាងម៉េចខ្លះ ដូចថាការតស៊ូនៅសម័យនឹង ពីព្រោះកាលពីមុនឆ្នាំ៧៥ កន្លែងនឹងកន្លែងតស៊ូកន្លែងបដិវត្តអីចឹង ។

នឿន ៖ ប៉ុនកាលនឹងខ្ញុំវ័យក្មេងៗដែរណា៎លោកគ្រូ ទើបចាស់ក្រោយនេះមក កាលយល់ដឹងវាចេះលោកគ្រូ ពេលនោះយើងមិនមែនជំហរទទួលខុសត្រូវខ្ពង់ខ្ពស់ឯងទាំងអស់ទេ ។ ការទៅមានគេបងៗចឹងទៅយើងចេះតែធ្វើម៉េចពេលនោះវាដូចជាព្រះអាទិត្យ ដែលរះឡើងទ្រដែនដី វាចឹងទាំងអស់ ។ ហើយបើយើងនៅស្រុកម៉ែឪក៏មានការលំបាករស់ ដូចគ្នា ។ ម៉ែនទេលោកគ្រូ?

ដានី ៖ បាទ! ទូទាំងប្រទេសចឹង ។

ដារ៉ា ៖ លោកពូកំណើតកើតជានៅ?

នឿន ៖ បាទ! ខ្ញុំកំណើតកើតជានៅស្រុកអឺ! ភូមិត្រពាំងឈូក ឃុំត្រពាំងធំខាងត្បូង ។

ដារ៉ា ៖ កាលដែលពេលពូចាប់កំណើតមកនឹងនៅក្នុងភូមិនឹង គឺគេដាក់ឈ្មោះត្រពាំងឈូកអីចឹង?

នឿន ៖ បាទ! ភូមិត្រពាំងឈូក ឃុំត្រពាំងធំខាងត្បូង ស្រុកត្រាំកក់ ខេត្តតាកែវ ។

ដារ៉ា ៖ អត់មានដូរភូមិ?

នឿន ៖ អត់មានទេ ។

ដារ៉ា ៖ តែខ្ញុំសួរមីងនៅខាងភូមិនោះ គាត់ថាភូមិនេះគេហៅភូមិ?

ដានី ៖ វាមាន២-៣ភូមិ គេថាភូមិត្រពាំងគល់?

ដារ៉ា ៖ មានគេថាមានតូចៗទើបយើងឥឡូវទេ ដែលដាក់មកភូមិត្រពាំងឈូក?

នឿន ៖ អូ! តូចៗបេះលោកគ្រូ ដូចថាយើងដូចថាទីក្រុងភ្នំពេញចឹង ដូចថាវត្តភ្នំគេហៅវត្តភ្នំ យើងថាកន្លែងនឹងដាកន្លែងធំមួយទៅ ក្បែរវត្តភ្នំដូចសាលាម៉េចហៅជាផារ ប៉ុនយើងរត់ពីភូមិៗ ។

ដារ៉ា ៖ ភូមិត្រពាំងធំ អឺ!ភូមិត្រពាំងឈូក ។

ដានី ៖ ភូមិត្រពាំងឈូកនឹងតាំងពីដើម មានឈ្មោះតាំងពីសង្គម?

នឿន ៖ បាទ! តាំងពីដើម ពីសង្គម ។

ដានី ៖ ដូចថាត្រពាំងគល់ អំពិលស្អីៗអានឹងគ្រាន់?

នឿន ៖ បាទ! អានឹងគ្រាន់ជានាម ។

ដានី ៖ មិនមែនជាភូមិពេញ?

នឿន ៖ បាទ!អត់ទេ អានឹងយើងរស់នៅជុំបៗ ដល់ចឹងហៅជានាម នេះស្រុកភូមិផ្ទះម៉ែខ្ញុំពីដើមខាងត្បូងវត្ត ត្បូងសាលារៀន របងទល់គ្នាពីខាងត្បូង ប៉ុនឥឡូវកន្លែងនឹងគេនៅផ្សេង យើងក្រោយ៧៩ នេះផ្ទះម៉ែខ្ញុំ ។

ដានី ៖ ជិតផ្ទះតាម៉ុកដែរ?

នឿន ៖ អត់ទេ ខាងនេះ ។

ដានី ៖ ផ្ទះយាយពូនៗខ្ញុំធ្លាប់មកជួបគាត់ដែរកាលពី?

នឿន ៖ ហ្នឹង ផ្ទះគាត់នៅខាងលិច ។ បើខ្ញុំនិយាយជាគ្នាមិនបានអីនេះ ពេលនោះខ្ញុំនៅក្មេងៗដែរ ។

ដានី ៖ អត់ទេ ខ្ញុំចង់ដឹងតែពីជីវិតរបស់លោកពូៗដឹង?

ដារ៉ា ៖ កាលពេលកើតជាពូរៀនសូត្រនៅក្នុងភូមិនឹងដែរ កាលនៅក្មេងៗ?

នឿន ៖ បាទ! រៀនបានតិច ដល់ក្រោយមកសង្រ្គាម ។

ដារ៉ា ៖ រៀនបានប៉ុន្មានឆ្នាំ បានមានសង្រ្គាម?

នឿន ៖ ហ៎! បានជិនាន់នឹងថ្នាក់ទី២ឥឡូវ ។

ដារ៉ា ៖ ថ្នាក់ទី២ឥឡូវ ពីមុនដូចថ្នាក់ទី១០?

នឿន ៖ ថ្នាក់ទី១១ ។

ដារ៉ា ៖ ថ្នាក់ទី១១?

នឿន ៖ យើងរៀនទី១២ ទី១១ ទី១០ចឹងណា ។

ដារ៉ា ៖ ពូចូលរៀនបានថ្នាក់ទី១១?

នឿន ៖ បាទ!

ដារ៉ា ៖ កាលនឹងអាយុប្រហែល៦-៧ឆ្នាំ?

នឿន ៖ បាទ!

ដារ៉ា ៖ ហើយអាយុប៉ុន្មានបានចូលរៀន?

នឿន ៖ អាយុ កាលជំនាន់នឹងគេច្រើនដាក់ដៃដល់ចឹង ។

ដារ៉ា ៖ ឲ្យដាក់ដៃដល់ត្រចៀក?

នឿន ៖ (សើច) យើងថា៦-៧ឆ្នាំ អស់លិតលោកគ្រូនោះ ពេលនឹង ។

ដារ៉ា ៖ ហើយរៀននៅសាលាណា?

នឿន ៖ សាលានឹង សាលាត្រពាំងធំនេះម៉ង ។

ដារ៉ា ៖ សាលាត្រពាំងធំនេះម៉ង?

នឿន ៖ បាទ! បឋមសិក្សា ។

ដារ៉ា ៖ ចឹងសាលានឹងវាមានពីមុនយូរមកហើយ?

នឿន ៖ តាំងពីដើម ។

ដារ៉ា ៖ ពូរៀនសាលានឹងបានថ្នាក់ទី១១មក ក៏មានសង្គ្រាម?

នឿន ៖ រដ្ឋប្រហារៗយើងរៀនតាម គ្រូរៀនតាមភូមិតាមដំបូក ។ លោកគ្រូដែលពុគេនិយាយទេ?

ដារ៉ា ៖ ធ្លាប់ពុមានរៀនតាមក្រោមដើមឈើមានអីចឹង ។ ចឹងពេលដែលមានរដ្ឋប្រហារឆ្នាំ៧០អានឹងពូ
នៅបានរៀនបានសូត្រអីទេ?

នឿន ៖ បានរៀន ម៉ារយៈដែរ ។

ដារ៉ា ៖ បានរៀនម៉ារយៈទៀត?

នឿន ៖ បាទ!

ដារ៉ា ៖ រៀននឹងរៀនតាមសាលារៀន តាមម៉េច?

នឿន ៖ បាទ! តាមសៀវភៅដែលយើងពីមុនមក ។

ដារ៉ា ៖ តែគ្រាន់មិនរៀននៅក្នុងសាលាទេ?

នឿន ៖ បាទ! អត់មានសាលាទេ ប៉ុនយើងរៀនពេលនោះ សង្គ្រាមមានយន្តហោះ ។ លោកគ្រូដឹងថា ជំនាន់នោះ មានសង្គ្រាម មានយន្តហោះ ដល់ចឹងយើងរៀនស្ងាត់ៗកន្លែងណារៀងទំនង យើងមានជីកត្រង់សេរ យើងការពារ ។

ដារ៉ា ៖ រៀនបែបចឹងវិញ មិនមែនចូលសាលារៀនអីទេ?

នឿន ៖ ប៉ុនជិនាន់នឹងសុទ្ធអ្នកបេះ...។

ដារ៉ា ៖ ហើយពូរៀននឹង មានចាំគ្រូខ្លះទេ នៅតូចៗនឹង?

នឿន ៖ ចាំ ។

ដារ៉ា ៖ គ្រូអីខ្លះ?

នឿន ៖ កាលខ្ញុំនៅរៀននេះ ប៉ុនខ្ញុំអត់បានចាំនាមត្រកូលគាត់ លោកគ្រូហុំ ប៉ុនឥឡូវគាត់ស្លាប់ គាត់នៅប្រគាបនេះ ។

ដារ៉ា ៖ លោកគ្រូហុំ?

នឿន ៖ បាទ! លោកគ្រូហុំ ខាងស្ពាំដែបត់ទៅនោះ ។

ដារ៉ា ៖ ហ្នឹងលោកគ្រូរបស់ពូ?

នឿន ៖ បាទ! លោកគ្រូថ្នាក់ដំបូង ក ខ ស្រះអ ស្រះអា ។

ដារ៉ា ៖ ចុះឡើងមកទៀត លោកគ្រូណាបន្ត?

នឿន ៖ លោកគ្រូឆាយ ។

ដារ៉ា ៖ លោកគ្រូឆាយ?

នឿន ៖ បាទ! ថ្នាក់ទី១១ ប៉ុនគាត់ស្លាប់ហើយ ចាស់ៗអស់ ។

ដារ៉ា ៖ ចាស់ៗអស់?

នឿន ៖ បាទ!

ដារ៉ា ៖ ពេលដែលមកដល់មានសង្គ្រាមរដ្ឋប្រហារឆ្នាំ៧០នឹង ការរៀនសូត្រពូរៀនរបៀបដាលាក់កំបាំងអី ខ្លាចយន្តហោះទម្លាក់បឹង?

នឿន ៖ បាទ! ដល់ពេលនោះយន្តហោះ សង្គ្រាមកើតឡើង ។

ដារ៉ា ៖ បឹងរៀនបានប៉ុន្មានឆ្នាំទៀត បាន?

នឿន ៖ ខ្ញុំរៀនបានអឺ!តែឆ្នាំ មើលឆ្នាំ៧៣ ខែ១២ ។

ដារ៉ា ៖ ខែ១២ ឆ្នាំ៧៣?

នឿន ៖ បាទ!

ដារ៉ា ៖ លែងរៀនកើត?

នឿន ៖ បាទ! ដល់ពេលនឹងក៏សង្គ្រាមខ្លាំងលោកគ្រូ យន្តហោះក៏ខ្លាំង ។

ដារ៉ា ៖ សង្គ្រាមប្រទាញប្រទុង?

នឿន ៖ បាទ! ភ្នំយើងវ៉ាន់យន្តហោះទម្លាក់ អត់មានធម្មតា មានអាតូច មានអាធំ មានអាកន្ទុំរុយ យើងហៅអាឌីកៗនោះ ។

ដាភ៉ា ៖ ដល់ចឹងទៅឆ្នាំ៧៣ ខែ១២ អត់បានរៀនគទៅទៀត ពូទៅ?

នឿន ៖ បាទ! ដល់ពេលនោះក្រោយមក ខ្ញុំក៏ពេលនោះយើងមិនអាចនៅក្នុងស្រុកភូមិបាន នៅតែម៉ែឪ ដល់អីចឹងទៅ ខ្ញុំទៅនៅខាងម៉ាដួរអមលាំង តាំងពោធិ៍ លោកគ្រូ ។

ដាភ៉ា ៖ ម៉ាដួរអមលាំង តាំងពោធិ៍?

នឿន ៖ បាទ! កំពង់ស្ពឺនឹងលោកគ្រូ ។

ដាភ៉ា ៖ ចូលដល់កំពង់ស្ពឺ?

នឿន ៖ បាទ! ទៅនៅតូចៗជំនាន់នឹង ចេះតែទៅ ។

ដាភ៉ា ៖ ទៅជាមួយគេ ជាមួយឯង?

នឿន ៖ បាទ!

ដាភ៉ា ៖ ទៅនឹងទៅដោយសារតែមានសង្គ្រាមទម្លាក់គ្រាប់បែក ឬក៏?

នឿន ៖ ពេលនឹងសង្គ្រាមលោកគ្រូ យើងនៅជុំគ្នាអត់បាន ដល់ពេលចឹងម៉ែឪក៏គាត់លាក់ខ្លួនតាមដំបូកតាមរូង ព្រៃ យើងមិនអាចនៅក្នុងភូមិធំៗបានទេ ។

ដាភ៉ា ៖ ចុះដល់ពេលទៅដល់អមលាំងហើយ ពូអាយុប៉ុន្មាន?

នឿន ៖ កាលនឹងអាយុ១២ ។

ដាភ៉ា ៖ ១២ឆ្នាំ?

នឿន ៖ បាទ! ១២ឆ្នាំ ។

ដាភ៉ា ៖ ទៅៗមានក្រុមមានគងអីទៅជាមួយ?

នឿន ៖ បាទ! ទៅជាមួយស្រករៗខ្ញុំនឹង ហើយនឹងមនុស្សធំៗខ្លះ ។

ដាភ៉ា ៖ នឹកឃើញម៉េចទៅអមលាំង?

នឿន ៖ កាលជំនាន់នឹងដល់សង្គ្រាមខ្លាំងចឹងទៅ ហើយយើងនៅតាមមូលដ្ឋាន វាមិនបានត្រង់ថាពេលនោះបងៗចេញអស់ ថាយុវជន និងយុវនារី កាលជំនាន់នឹង ហើយដល់ពេលចឹងយើងមិនអាចនៅជុំជាមួយឪពុកម្ដាយបាន ។

ដាភ៉ា ៖ ចឹងនៅក្នុងពេលនឹងគឺតម្រូវត្រូវតែចេញពីឪពុកម្ដាយ ព្រោះយើងអាយុ១២ឆ្នាំ ជាយុវជនយុវអីចឹង?

នឿន ៖ បាទ! យើងមិនអាចនៅបាន ត្រង់ថាពេលនោះសង្គ្រាមផង ហើយដល់ពេលចឹងទៅដឹកនាំតាមមូលដ្ឋានខាងភូមិនោះក៏ចេញ ខាងនោះចេញ ដូចយើងទៅកាត់ដេរឥឡូវចឹង បាទ! វាចឹង ។

ដាភ៉ា ៖ ដល់ចឹងចេះទៅតាមគ្នាទៅ?

នឿន : បាទ! បេះទៅតាមគ្នាទៅ ។

ដារ៉ា : គេថាទៅអមលាំងបេះទៅគេឯងទៅ?

នឿន : បាទ!

ដារ៉ា : កាលទៅជំនាន់នឹង គ្នាពូប៉ុន្មាននាក់អីដែរ?

នឿន : គ្នាខ្ញុំស្លាប់អស់ ។

ដារ៉ា : ទៅច្រើនគ្នា?

នឿន : បាទ! ទៅគ្នា៧នាក់ ប៉ុនស្លាប់អស់ហើយ គាត់ខ្លះទៅលេងកូន ប៉ុនដល់ទៅបានគ្នាបេះទៅ ។

ដារ៉ា : ដល់ពេលដល់អមលាំងក្នុងឆ្នាំណា?

នឿន : ឆ្នាំនឹងដដែល ។

ដារ៉ា : ឆ្នាំ៧៣?

នឿន : បាទ! ៧៣ ខែ១២ ខែយើងច្រូត កំពុងចែកស្រូវម្នាក់ៗបាន១២ថាំង ។

ដារ៉ា : កាលនឹងគេនៅចែកស្រូវ?

នឿន : បាទ! នៅចែកស្រូវ ហូបបាយតាមគ្រួសារ ។

ដារ៉ា : ដល់ពេលដល់អមលាំង ការរស់នៅយ៉ាងម៉េច?

នឿន : ដល់អមលាំង ខ្ញុំគេថាយកទៅរស់នៅកន្លែងកុមារ ប៉ុនដល់ពេលនេះ មានបងៗគេអ្នកស្គាល់ គេហៅទៅនៅមន្ទីរពេទ្យ ។

ដារ៉ា : ពេលចេញទៅ ដល់អមលាំងមានកងកុមារគេផ្សេង?

នឿន : បាទ!កងកុមារ ហើយដល់ពេលខ្ញុំទៅផុតមុននឹង អ្នកដែលទៅពីក្រោយគ្នាហួសៗនឹង ដល់ចឹង ខ្ញុំនៅជាមួយអ៊ំមួយ ពូដែលគាត់ទៅលេងកូននឹងដែលគាត់ស្គាល់គ្នា ដល់ហើយហៅមកនៅ មន្ទីរពេទ្យមក ។

ដារ៉ា : គាត់ឈ្មោះអី?

នឿន : មន្ទីរពេទ្យពេលនោះ គាត់ហាន់ណូយដែរ អ៊ំសែតៗ ។

ដារ៉ា : អ៊ំសែត?

នឿន : បាទ!

ដារ៉ា : គាត់ខ្មែរមកពីហានណូយ គាត់រត់ដល់អមលាំង?

នឿន : អត់ទេ គាត់នៅមន្ទីរពេទ្យនឹង ។

ដារ៉ា : នៅមន្ទីរពេទ្យអមលាំង?

នឿន : បាទ! មន្ទីរពេទ្យអមលាំង ។

ដារ៉ា : ស្អីគេសែត?

នឿន : អត់ចាំត្រកូលទៀត ពេលនឹងក្មេងៗលោកគ្រូ ដូចថាមិនចាប់អារម្មណ៍ដល់ ។

ដារ៉ា : ឈ្មោះសែតនឹងឯង ឃើញពូយកទៅធ្វើការនៅពេទ្យ ហើយម៉េច?

នឿន : ដែលអ្នកស្គាល់ៗនៅកន្លែង ដូចខាងកន្លែងលោកគ្រូចឹង ពេលឃើញចឹងក៏ *"អឺ!អាឯងយកវាទៅនៅមន្ទីរពេទ្យផង វាក្មេងៗគេសង្គ្រាមបាញ់គ្នា"* ដល់ចឹងខ្ញុំទៅនៅនឹង ក៏កើតជាចេះនៅជាប់នឹងពេទ្យនឹង ។

ដារ៉ា : នៅជាមួយតាសែតនឹង?

នឿន : បាទ!

ដារ៉ា : ហើយការងារនឹងនៅអមលាំង?

នឿន : អមលាំង ។

ដារ៉ា : ហើយការងារពូនៅក្មេងអាយុ១២ គេឲ្យធ្វើអី?

នឿន : នៅក្មេងគេប្រើការងារ អត់ទាន់ច្បាស់លាស់ជាការងារសំខាន់ទេ ។

ដារ៉ា : ជាការងារប្រចាំ ក្មេងនឹងគេឲ្យធ្វើអីខ្លះ?

នឿន : ដល់ក្រោយមកចុះមកក្រោមអមលាំងៗយើងចូលដល់ដំបូង អមលាំង ចុះមកតាំងពោធិ៍ ចុះមកក្រោមចឹង ។ ដល់ពេលក្រោយមកចឹង នៅមន្ទីរពេទ្យគេចេះប្រើ យើងក្មេងៗប្រើឲ្យដឹកទឹកឲ្យគេ គេប្រើឲ្យមើលម៉ាស៊ីនភ្លើងឲ្យគេចឹងទៅ ចេះធ្វើទៅបើយើងនៅតូចៗ ។

ដារ៉ា : បើគិតរាប់ទៅប៉ុន្មានមុខការងារ?

នឿន : បាទ! ច្រើនណាស់លោកគ្រូ អាការងាររកកំណត់មិនឃើញ យើងមិនទាន់មានមុខការសំខាន់ ព្រោះអី ពេលនឹងក្មេងៗ ។

ដារ៉ា : នៅក្មេងចឹង គេអនុញ្ញាតឲ្យនៅក្នុងបរិវេណពេទ្យនឹង?

នឿន : បាទ!

ដារ៉ា : អនុញ្ញាតិឲ្យដើរអីមើលឃើញមានរបួស អ្នករបួស អ្នកអី?

នឿន : បាន អត់អីទេ ព្រោះអីមន្ទីរពេទ្យនឹងលោកគ្រូ ខ្ញុំមានប្រសាសន៍ទៅ ខ្ញុំនិយាយការពិតបាទ!សុំអធ្យាស្រ័យ ព្រោះអីបើលោកគ្រូមានការសាកសួរពីដំណើរការអំពីដំណើររឿងជីវិតទៅមិន យកទោសពៃរ៍អីដល់ស្លាប់ ដល់ប្រពន្ធកូនទេណា លោកគ្រូ ។

ដារ៉ា : អត់ទេ ពួកខ្ញុំចង់ដឹង ចឹងបានខ្ញុំសួរដេញដោលពូ ។

នឿន : ដល់ចឹងទៅលោកគ្រូ ពេលនោះមន្ទីរពេទ្យនឹង គេហៅមន្ទីរពេទ្យចល័តៗបានន័យដូរមុខ ដល់ពេលកងទ័ពសង្គ្រាមខាងមុខ ។ ហើយយើងចល័តបានន័យថា ឧទាហរណ៍ថាសង្គ្រាមអន្កតា

សោម គាកែវ ចល័តនៅដូចជាម្ដុំយើងខាងលិចវត្ត គ្នាប្រហែលជា៤០នាក់ មន្ទីរពេទ្យណឹង ។

ដារ៉ា ៖ ធំដែរ?

នឿន ៖ បាទ! ចល័តៗ ឧទាហរណ៍ របួសចូលមកធ្ងន់ ជម្ងឺធ្ងន់ សង្គ្រោះហើយ វាអាចថាទំនងធូរហើយមិនអាចដល់ស្លាប់ យើងមានស្នាក់ការសែងមានមន្ទីរពេទ្យធំ មកជិតមកអមលាំង តាំងពោធិ៍ គេហៅមន្ទីរប្រកក្រសាំងៗ ខ្ញុំឥឡូវក៏ភ្លេចដែរ ខេត្តកំពង់ឆ្នាំងៗកំពង់ស្ពឺជាប់គ្នានឹង ។

ដារ៉ា ៖ មន្ទីរប្រកអីគេ?

នឿន ៖ ប្រកក្រសាំង ។

ដារ៉ា ៖ អានឹងជាមន្ទីរពេទ្យធំ?

នឿន ៖ បាទ! មន្ទីរពេទ្យធំ ប៉ុន្ដខ្ញុំមិនអាចស្គាល់ផ្ទៃក្នុងទាំងអស់ដែល គ្រាន់តែមកលេងម្ដងម្កាលគ្រាន់តែឃើញហើយក៏ ធម្មតាយើងក្មេងៗវាមិនខុសអីដើរលេងបុណ្យ ។

ដារ៉ា ៖ ដល់ពេលមានរបួសនៅពេទ្យជួរខាងមុខ ពេទ្យចល័តនឹង?

នឿន ៖ បាទ! ពេទ្យចល័ត ។

ដារ៉ា ៖ ពេទ្យចល័តគេដោះស្រាយនៅកន្លែងនឹងសិន?

នឿន ៖ ដោះស្រាយ បាទ! ។

ដារ៉ា ៖ បើសិនជាធ្ងន់អីម៉េច គេព្យាបាលហើយ ចាំយើងអាចបញ្ជូនមកពេទ្យ?

នឿន ៖ កាត់ជើង កាត់ដៃ វះ ដោះស្រាយសព្វគ្រប់បានហើយ ទុកព្យាបាលនៅនឹង បើថាលែងអីហើយបញ្ជូនទៅមន្ទីរប្រកក្រសាំង ។

ដារ៉ា ៖ អានឹងដូចជាពេទ្យជួរមុខ ដើម្បីសង្គ្រោះបន្ទាន់?

នឿន ៖ បាទ! ជួរមុខ ។

ដារ៉ា ៖ ចុះពូធ្លាប់ចូលរួមនៅនឹង ប៉ុន្មានឆ្នាំ?

នឿន ៖ ខ្ញុំនៅនឹង នៅរហូតនៅដល់ឆ្នាំមើល៧៣ហើយ៧៤លោកគ្រូ?

ដារ៉ា ៖ បាទ!

នឿន ៖ នៅនោះបានដល់ឆ្នាំ៧៤ៗក្រោយមកដូរកន្លែង មន្ទីរពេទ្យចល័តនឹងដូរ ។ មន្ទីរពេទ្យធំគេនៅដដែល អាចល័តនឹងឧទាហរណ៍ថា កងទ័ព កងពល នឹងទៅខាងណាខាងព្រំប្រទល់ពោធិ៍សាត់ កំពង់ឆ្នាំង ម៉ាដូរពង្រៗ លោកគ្រូដែលស្គាល់ ទេ ម៉ាដូរនឹង?

ដារ៉ា ៖ អូ! ពង្រនៅកំពង់ឆ្នាំង?

នឿន ៖ បាទ! ប៉ុនឥឡូវខ្ញុំភ្លេចអស់ច្រើនហើយ គ្រាន់តែនិយាយគោលៗ អាព្រំប្រទល់ពោធិ៍សាត់ពង្រនឹង យើងឡើងមកលិចមក គេហៅត្រពាំងម្លូត្រពាំងអីបៀតភ្នំពាមលោក ។ លោកគ្រូដែលព្ទុដែរ?

ដារ៉ា ៖ ធ្លាប់ព្ទុដែរ ។

នឿន ៖ បាទ! ខ្ញុំវាចាំមិនអស់ ។

ដារ៉ា ៖ តែរឿងភូមិសាស្រ្តទៅដល់ៗមិនដឹង ប៉ុនគ្រាន់យើងធ្លាប់ព្ទុ ។

នឿន ៖ បាទ! ឲ្យតែព្ទុយ៉រៗ ខ្ញុំវាភ្លេចច្រើនពីមុនយល់ចាំច្រើនដែរ ។

ដារ៉ា ៖ បានន័យថាពូនៅក្នុងពេទ្យចល័ត?

នឿន ៖ បាទ! នៅចល័តនឹងរហូត ។

ដារ៉ា ៖ ជាមួយតាសែតនឹង?

នឿន ៖ បាទ!

ដារ៉ា ៖ បើសិនជាកង់ទ័ពទៅដល់កន្លែងណា ពេទ្យចល័តចេះចល័តតាម?

នឿន ៖ បាទ! ហើយដល់របួសនឹង យើងសង្រ្គោះទៅ ។

ដារ៉ា ៖ បានមកពេទ្យ?

នឿន ៖ មកពេទ្យមូលដ្ឋានធំៗគេ នៅជ្រៅៗ ។

ដារ៉ា ៖ ដល់ពេលឆ្នាំ៧៨ ពូដូរទៅចល័តទៅកន្លែងផ្សេងមួយទៀត?

នឿន ៖ បាទ! ទៅកន្លែងមិញនឹង ។

ដារ៉ា ៖ កន្លែងមិញនឹងគឺ?

នឿន ៖ មើលកន្លែងចន្លោះនឹងនៅ លោកពូដែលស្គាល់វត្តចំបក់ខ្សាច់ ម៉ាដូរកំពង់ឆ្នាំង ប៉ុនព្រំប្រទល់ពោធិ៍សាត់ អាជិតមកភ្នំពាមខ្ញុំថាមិញ អានឹងចល័តនៅត្រង់នឹង ។

ដារ៉ា ៖ នៅពេលដែលនៅជាមួយពេទ្យចល័តចឹង ពូធ្លាប់សែងរបួស សែងទាហានអី?

នឿន ៖ អត់ទេ តូចៗគេអត់ឲ្យសែង គេអត់ឲ្យវីវរវល់រឿងហ្នឹង ។

ដារ៉ា ៖ តែគ្រាន់ពូបានឃើញទិដ្ឋភាពនឹង?

នឿន ៖ បាទ! គ្រាន់បានឃើញ ។

ដារ៉ា ៖ ហើយចុះក្រោយមកទៅ?

នឿន ៖ ដល់ពេលក្រោយមក មន្ទីរពេទ្យចល័តនៅកន្លែងនឹងបានដល់ឆ្នាំ ពាក់កណ្តាល៧៨ កាលនឹងគេធ្វើសង្រ្គាមជាមួយទាហានលន់ នល់ ។ នៅម៉ាដូរព្រំប្រទល់ពោធិ៍សាត់ ម៉ាដូរខេត្តកំពង់ឆ្នាំង

ប៉ុនយើងវាកមកលិច ឧទាហរណ៍ថាពោធិ៍សាត់ចឹងមក កំពង់ឆ្នាំងចឹង សង្គ្រាមនឹងវានៅខេត្ត នៅចឹង ។

ដារ៉ា ៖ ជ្រុលរុលរហូតចឹង?

នឿន ៖ បាទ!

ដារ៉ា ៖ រហូតដល់?

នឿន ៖ រហូតដល់ក្រោយមកឆ្នាំអី! ចុង៧៨លោកគ្រូ ប្រហែលជាខែ មើលជំនាន់នោះស្រូវបែកគុម្ព ស្រូវប្រហែល ជិតច្រូតលោកគ្រូ ។

ដារ៉ា ៖ ជិតច្រូត វាចូលក្នុង?

នឿន ៖ ខែ១១, ១២នឹងជូរមកវិញ ។

ដារ៉ា ៖ ជូរមកណាវិញ?

នឿន ៖ មកនៅអី! កន្លែង ភ្លេចហើយ អានឹងយើងមកដល់ខាងត្បូងភ្នំបាសិត ។

ដារ៉ា ៖ ផ្លូវភ្នំបាសិត ជិតចូលដល់ភ្នំពេញ?

នឿន ៖ បាទ! ប៉ុនអាផ្លូវនឹង ផ្លូវ២៦លោកគ្រូ?

ដារ៉ា ៖ ភ្នំបាសិត២៦ ២០អី ។

ដារ៉ា ៖ ហើយមកដល់កន្លែងភ្នំបាសិត?

នឿន ៖ មើលលោកគ្រូកន្លែងនឹង ខ្ញុំភ្លេចហើយ នៅក្នុងទឹកដីកំពង់ស្ពឺ ។

ដានី ៖ ផ្លូវ៥៦ ផ្លូវណា?

នឿន ៖ ពីខាងលិច ។

ដារ៉ា ៖ ពីខាងលិចអី?

នឿន ៖ មូលដ្ឋានប្រជាជនពីខាងលិច ។

ដានី ៖ ជិតបាត់ដឹងអីនឹង?

នឿន ៖ ដល់ពេលយើងជិះអីមកៗអាផ្លូវនឹងបានយើងមក ខ្ញុំភ្លេចហើយកន្លែងនឹង ។

ដារ៉ា ៖ មិនអីទេ គ្រាន់ដឹងថាពួមកដល់មុំភ្នំបាសិតនឹងហើយ?

នឿន ៖ ខាងលិចនឹង ។

ដារ៉ា ៖ ខាងលិចភ្នំបាសិត?

នឿន ៖ បាទ! ដល់នឹងម៉ារយៈសង្គ្រាមនឹង ប្រទាញប្រទុងគ្នាវាចូល៧៥ ។

ដារ៉ា ៖ វាខ្លាំងមែនទែន?

នឿន ៖ បាទ!

ដារ៉ា ៖ អានឹងតែរើមកវារុលចូលមកៗភ្នំពេញ ឥឡូវរុលខាងលិចភ្នំបាសិត ជិតចូលដល់ព្រៃកញ្ចៅ ម៉ាដួរចេញមកព្រៃកញ្ចៅ?

នឿន ៖ ចាំរាល់ថ្ងៃកន្លែងនឹង ប៉ុនឥឡូវភ្លេច ប៉ុនយើងមកតិចមក ចូលមកផ្លូវ២៦ឡើងមកភ្នំបាសិតៗ យើងចុះមកផ្លូវលេខ៤ មកពោធិ៍ចិនតុង ប៉ុនខ្ញុំភ្លេចកន្លែងនឹង។ មកដល់កន្លែងនឹងគេឲ្យយើងមើលអ្នកឈឺអ្នកអីខ្លះ។

ដារ៉ា ៖ ហ្នឹងហើយពូធំតិចហើយ?

នឿន ៖ ធំតិចហើយ ប៉ុនយើងអត់ទាន់មានជំហរម្ចាស់ការទាំងស្រុងទេ។

ដារ៉ា ៖ តែម៉ារយៈពេលដែលពូនៅជាមួយពេទ្យចល័ត ជាមួយតាសែតអីមានការបណ្ដុះបណ្ដាលកុមារឲ្យចេះវិជ្ជាពេទ្យអីម៉េច?

នឿន ៖ កុមារការពិតមានតិច គេបណ្ដុះបណ្ដាលដែរ មិនមែនថាមិនគិតទេ ប៉ុនគ្រាន់ថាយើងនៅតូចៗមានគ្នាតិច ដល់ចឹងយើងdirectទៅវាអត់មានវគ្គ។ ឧទាហរណ៍ថាឥឡូវមន្ទីរពេទ្យចល័តចែកជា៣ ឬជា៤វេណ វេណទី១អ្នកជាំបាយ វេណទី២អ្នកលាងរបួស វេណទី៣អ្នកព្យាបាលចាក់ ថ្នាំ វេណទី៤អ្នកគេវះកាត់។ ហើយពេលចឹងទៅ ខ្ញុំនៅវ័យតូចនឹងក៏បងៗគេប្រើឲ្យយើង ពេលវះកាត់ ឲ្យយើងរៀនវាស់ឈាម អានឹងយើងស្គាល់លេខស្គាល់អត្តប្រដាប់វាស់ឈាម ខ្លះចឹងទៅ ពេលក្រោយមកឲ្យចាក់ថ្នាំខ្លះទៅ ចាក់សាច់ដុំយាងម៉េច សរសៃរយ៉ាងម៉េច សារ៉ូយ៉ាងម៉េច លាងរបួសរុំយ៉ាងម៉េច បន្តាត់បង្រៀនទៅ។ ដល់ពេលចឹងមានការយល់ដឹងពីពេទ្យនឹងតិចៗទៅលោកគ្រូណា៎។

ដារ៉ា ៖ ហើយក៏បានធ្វើការចូលរួមរហូតតទៅ?

នឿន ៖ បាទ! គ្រាន់យល់តិចតួច បាទ!ចូលរួម។ រហូតដល់ពេលយើង៧៥ អាថ្ងៃឈ្នះភ្នំពេញថ្ងៃ១៧មេសានឹង ដល់ពេលនឹងជិះឡានជិះអីមកនឹងគេនឹងឯង មកតាមផ្លូវខ្ញុំថាផ្លូវ២៦ឡើងមកភ្នំបាសិត ប៉ុនខ្ញុំភ្លេចកន្លែងនឹងៗទឹកដីកំពង់ស្ពឺកន្លែងនឹង ដល់នឹងមិននៅវត្តជំពូវន្តយើង។ លោកគ្រូស្គាល់អត់?

ដារ៉ា ៖ បាទៗវត្តជម្ពូវ័ន្ត។

នឿន ៖ អនុវិទ្យាលជម្ពូវ័ន្តនឹង។

ដារ៉ា ៖ ឥឡូវវិទ្យាល័យហើយ។

នឿន ៖ ឥឡូវ ពេលមកដល់គេសុំស្នាក់មន្ទីរពេទ្យ អាពេទ្យចល័តមុននឹងនៅកន្លែងនឹងបានប្រហែលជាជិតម៉ាឆ្នាំ។

ដារ៉ា ៖ ចឹងនៅពេទ្យសែតនឹងដដែល?

នឿន ៖ បាទ!

ដារ៉ា ៖ ឈ្មោះសែតនឹងដដែល?

នឿន ៖ ប៉ុនដល់ក្រោយមកអ៊ំសែតនឹងគេដូរ ។

ដារ៉ា ៖ មកដល់កន្លែងណាបានគេដូរ?

នឿន ៖ កន្លែងយើង ។

ដារ៉ា ៖ ជម្ពូវ័ន្ត?

នឿន ៖ បាទ!

ដារ៉ា ៖ គេដូរម៉ាដំណាក់ទៅទៀត?

នឿន ៖ បាទ! គេដូរ ដល់ពេលនឹងវា មន្ទីរពេទ្យនៅកន្លែងនឹង ហើយកន្លែងនឹងគេហៅកងពលលេខ១
លោកគ្រូពីសង្រ្គាមមុន កងពលលេខ១ភូមិភាគយើងនិយាយតាមភូមិភាគបស្ចិម-និរតី ។

ដារ៉ា ៖ ភូមិភាគបស្ចិម?

នឿន ៖ បាទ! បស្ចិម និរតីក៏នៅរួមនៅនឹងដែរ ។ ដល់ពេលយើង៧៥គេបែកគ្នា អ្នកខ្លះមកខេត្ត
តាកែវ ធ្វើពេទ្យនៅខេត្តតាកែវ ។ ហើយដល់ទីអនុវិទ្យាល័យនៅវត្តជម្ពូវ័ន្តនឹងស្នាក់ អាពេល
នឹងគេឲ្យ ខ្ញុំមើលម៉ាស៊ីនភ្លើងវិញ ។

ដារ៉ា ៖ ចឹងវិញ?

នឿន ៖ បាទ!

ដារ៉ា ៖ នៅកន្លែងជម្ពូវ័ន្តនឹង?

នឿន ៖ បាទ! ជម្ពូវ័ន្ត ម៉ាស៊ីនភ្លើងមួយធំ គ្នាខ្ញុំ២នាក់ ។

ដារ៉ា ៖ ស្គាល់ឈ្មោះមិត្តភ័ក្តពូ?

នឿន ៖ ស្លាប់ហើយ ។

ដារ៉ា ៖ ឈ្មោះអីគេ?

នឿន ៖ សាវឿន១ គាត់អាយុច្រើនជាងខ្ញុំប្រហែល៣ឆ្នាំ ស្រុកកំណើតនៅកំពង់ឆ្នាំង តែស្លាប់ ។

ដារ៉ា ៖ ម៉ាស៊ីនភ្លើងសម្រាប់ស្អី?

នឿន ៖ សម្រាប់មន្ទីរពេទ្យនឹង ។

ដារ៉ា ៖ អូ! សម្រាប់បំភ្លឺនៅកន្លែងមន្ទីរពេទ្យនឹង?

នឿន ៖ បាទ! គ្រប់អគារទាំងអស់ ។

ដារ៉ា ៖ ម៉ាស៊ីនភ្លើង១ម៉ាកអីគេ?

នឿន ៖ អានឹងកងយោង២ធំ លោកគ្រូ ម៉ាកស្អីទេកាលនឹង ខ្ញុំភ្លេចហើយ ។

ដារ៉ា ៖ បើពូ ទោះបីមកដល់ឆ្នាំ៧៥ ពូអាយុប្រហែលជា?

នឿន ៖ ១៥ឆ្នាំ ។

ដារ៉ា ៖ ១៥ឆ្នាំ ដូចបើថាមើលម៉ាស៊ីន បញ្ចេះម៉ាស៊ីនម៉េចរួច?

នឿន ៖ អត់ទេ ដែលបង១ ។

ដារ៉ា ៖ បងថាឈ្មោះសារឿន គាត់ធំជាង?

នឿន ៖ បាទ! យើងជួយទប់ជួយទាញគ្នា ជួយតខ្សែអំពូលអី យើងយល់ ។

ដារ៉ា ៖ ទៅចិនវិញ?

នឿន ៖ បាទ! ដល់ពេលក្រោយមកចិន បានខ្ញុំផ្លាស់ពីនឹងនៅលផ្នែក អនុវិទ្យាល័យនឹង គ្រាន់ស្នាក់ប៉ុន្មានជិតម៉ាឆ្នាំ ។

ដារ៉ា ៖ ហ្នឹងចូលឆ្នាំ៧៦?

នឿន ៖ បាទ! ៧៦ ។

ដារ៉ា ៖ ចូលឆ្នាំ៧៦ ខែប៉ុន្មានបានទៅលផ្នែក?

នឿន ៖ ខែដូចខែដើមឆ្នាំ ។

ដារ៉ា ៖ ដើមឆ្នាំ៧៦?

នឿន ៖ បាទ! យើងស្មានៗលោកគ្រូ បើដើមឆ្នាំមិនហួសពីខែ៣ ខែ៤ ប្រហែលប៉ុននឹង ខ្ញុំអត់បានកត់ត្រាដែរ ពេលនោះវានៅស៊ើរៗដែរ ។

ដារ៉ា ៖ ចាំប៉ុននឹង បានន័យថាចាំល្អ ។

នឿន ៖ ដល់ពេលមកនៅលផ្នែកនឹង មកនៅលផ្នែកមកនៅអាកន្លែង ។ លោកគ្រូដែលទៅហ្នឹងអត់? លោកគ្រូដែលស្គាល់បន្ទាយ ប៉ាវ៉ានឹងអត់?

ដារ៉ា ៖ ធ្លាប់ទៅវត្តត្រឡែងកែង?

នឿន ៖ វត្តត្រឡែងកែងចុះមកក្រោម វត្តត្រកែងវត្តលោកយ័ន្តជិតដៃព្រែកទន្លេ ព្រែកក្រោមលោកគ្រូណា៎ ។ ហើយនេះផ្លូវលេខ៥ អាកន្លែងនេះគេហៅបន្ទាយប៉ាវ៉ា យើងច្រើនបទចំរៀងជិនាន់សៀមបាចប្រាក់ដូងមិនបុស្សីច្រើនណាស់ ។ ហើយដល់បន្ទាយប៉ាវ៉ាចិន មិនមានអាផ្លូវចុះមកលផ្នែកក្រោមនេះ អានេះផ្លូវលេខ៥ទៅកំពង់ឆ្នាំង ។ ចិនមកលផ្នែកក្រោមលោកគ្រូមានឃើញអគារវែង១រោងចក្រវែង១អត់ អានឹងដាក់មន្ទីរពេទ្យនៅនឹង ។ ហើយអគារសង់ដោយប្រក់ក្បឿង ហើយចាក់សាបខ្ពស់១ច្រើនណាស់ ប្រហែល១០អគារ ។

ដារ៉ា ៖ មានតាំងពីពេលនឹងមក?

នឿន ៖ បាទ! ដល់អគារវែងៗនឹងពីដើមទេ ដាក់ដែលស្នាក់នឹងម៉ារយៈ តែអគារសាងថ្មី គឺកសាងថ្មី ប្រហែល១០ ជិត២០ដាក់របងស្អីស្អាតណាស់ ប្រក់ដោយក្បឿងចាក់សាបស៊ីម៉ង់ ជញ្ជាំងក្តារ អានឹងសម្រាប់អ្នកឈឺ សម្រាប់បុគ្គលិកពេទ្យប្រុសស្រីយើងដាក់នឹង។ រួចហើយក៏ចាប់ផ្តើមនៅនឹងបាន ត្រូវធ្វើស្រែទៀតហើយ ភ្ជួររាស់។

ដារ៉ា ៖ ពេទ្យតែធ្វើស្រែភ្ជួររាស់?

នឿន ៖ បាទ! ការងារដូចខ្ញុំជម្រាបលោកគ្រូពីដើម ចាប់ឆាយ គេឲ្យធ្វើអីក៏ធ្វើ មិនមែនធ្វើតែខ្ញុំអ្នកណានេះក៏ធ្វើប្តូរគ្នាទៅ។ ប៉ុនខ្ញុំធ្វើចឹង ហើយក្រោយមកគេឲ្យនៅក្រុមថ្នាំ ផលិតថ្នាំ។

ដារ៉ា ៖ ផលិតថ្នាំវិញ?

នឿន ៖ បាទ!

ដារ៉ា ៖ ក្រុមផលិតថ្នាំនឹងមានការងារយ៉ាងម៉េច?

នឿន ៖ បាទ! ផលិតថ្នាំនឹង យើងនៅវ៉យស៊្វើរនឹងក៏ចាប់ផ្តើមយើងប្រើអាចំហុយទឹក បិទទឹកដូចគេបិទស្រា ប៉ុនគេ មានគ្រូគេច្បាស់លាស់។ ផលិតថ្នាំចាក់ ថ្នាំលេប ថ្នាំបណ្តក។

ដារ៉ា ៖ បិទបំនិតជាទឹក?

នឿន ៖ បាទ! ដល់ពេលអានឹងគេហៅទឹកនឹងទឹកសុទ្ធហើយណា។

ដារ៉ា ៖ ដូចយើងបិទស្រា ចេញទឹក?

នឿន ៖ បាទ! ដូចបិទស្រា យកអាទឹកលេខ១ប៉ុនយើងបិទតម្រូវថ្នាំ។ ក្រោយមកចាប់ផ្តើមផលិតថ្នាំជាមួយបងនារីម្នាក់នឹងគាត់មេក្រុម ឈ្មោះខ្ញុំអត់ចាំនាមត្រកូល ឈ្មោះបងរីៗនៅកំពង់ឆ្នាំង គេហៅស្រុក១០ៗ ជំនាន់នឹងដឹងគេហៅស្រុក១០។

ដារ៉ា ៖ ស្រី រីនឹង?

នឿន ៖ បាទ! ខ្ញុំបែកពីគាត់ អត់ដឹងគាត់ស្លាប់រស់។

ដារ៉ា ៖ ផលិតថ្នាំគេផលិត?

នឿន ៖ ផលិតចុះលោកគ្រូ ថ្នាំនឹងមានអាមេ្សវាមកពីបរទេស ដល់ពេលនេះគ្រូមានក្បួនរបស់គាត់អាណាត្រូវថ្លឹងពីប៉ុន្មានដល់ប៉ុន្មាន។ ប៉ុនគ្រាន់យើងគ្រាន់ថា បងអ្នកម្ចាស់ការ យើងជំនួយការពីខាងក្រោយ ហើយក៏មិនបានចាប់អារម្មណ៍ ចាំបានល្អិតល្អន់មកដល់ឥឡូវគ្រាន់តែយល់ការងារធ្វើនឹង។ ទាល់នៅនឹងបាន យើងកំពុងធ្វើស្រែស្ទូងនឹងលោកគ្រូ ៧៦វាចូល៧៧ចូល៧៨ អាខ្ញុំថាលផ្ទែកមិញ អាកន្លែងអគារវែង ដល់ពេលនឹងមិននៅអគារច្រើនកសាងផ្ទាល់ដៃជាងធ្វើសម្រាប់កន្លែង។ ក៏ចាប់ផ្តើម ខ្ញុំកំពុងភ្ជួររាស់ៗក៏ឃើញនារីម្នាក់ ក៏គាត់មកហៅថា "បងៗឲ្យហៅ" ខ្ញុំសួរថា "ហៅទៅណា?" ថា "ទៅនៅកើតកំពង់សោម" "ហ៎! កុំចេះហៅ ខោអាវ

សុទ្ធតែភក់” “អឺ!បេះថាមក” ចឹងបានខ្ញុំដាក់គោ ដាក់នង្គ័ល ។ ខ្ញុំមកដល់ ឡានគេរៀបអីវ៉ាន់ក៏ឡើងឡានមកនៅកើតកំពង់សោមឆ្នាំ៧៨ ។ ៧៨ខែធ្វើស្រែខែ៧ ខែ៨ កំពុងស្ទូងនឹងអត់ខុសខែ៧ ខែ៨ ។ ខ្ញុំមិនសូវ បានចាំល្អិតអស់ ព្រោះកន្លែងខ្លះខ្ញុំខានចាប់អារម្មណ៍ដែរកន្លែងស្នាក់ៗនៅ ។ ដល់៧៨ខ្ញុំជិះឡានមកនៅខាងកើតកំពង់សោម ។ លោកគ្រូដែលទៅផ្លូវកំពង់សោមគេហៅភូមិស្រែចាម ទៅដល់ខាងកើតទឹកសាបឆ្ងាយបន្តិចមក យើងទៅដល់វាលរេញចឹង ដល់វាលរេញទៅឲ្យឆ្ងាយតិចទៅនឹង ហើយឆ្វេងដៃឡើងទៅស្រែចាម គេហៅទៅកោះខ្យងកោះអីនឹង ។

ដារ៉ា : អូ! បាទ!កោះខ្យង ។

នឿន : បាទ! ភូមិស្រែចាមនឹងនៅនឹង ។

ដារ៉ា : នៅកោះខ្យងនឹង?

នឿន : បាទ! អានឹងនៅចល័តនឹងទៀត ។ បែកគ្នា ពេទ្យនឹងពេទ្យធំណាស់ក្រោយមក នៅលផ្នែកនឹងពេទ្យធំណាស់ ពេទ្យបូកគ្នាទាំងអស់ដូចខ្ញុំថាដល់បូកគ្នាបែកគ្នា ខ្លះមកនៅតាកែវ យើងបែកភូមិភាគបែកកងពលគ្នា ។

ដារ៉ា : គេបែកចេញពីលផ្នែកនឹងទាំងអស់?

នឿន : បាទ! លផ្នែកនឹងមូលដ្ឋានធំណាស់ អត់ទៅណា គ្រឹះនឹងហើយ ។ ហើយដល់ខ្ញុំមកនៅខាងកើតកំពង់សោមនឹងហៅស្រែចាមនឹង អានឹងចល័តមួយ ។ ហើយដល់ពេលមកនៅនឹងហើយ ខ្ញុំនៅផលិតថ្នាំទៀត ។

ដារ៉ា : ផលិតថ្នាំទៀត?

នឿន : បាទ! ធ្វើទៀតរហូតទៅដល់ឆ្នាំ៧៨ ៧៨ខែ រកនឹកខែសិន អត់ទាន់ប្រូត គ្រាន់ជិត ។

ដារ៉ា : ជិតប្រូត?

នឿន : បាទ!

ដារ៉ា : បើជិតប្រូតអាចនៅក្នុងខែ១០ ។

នឿន : ហើយលោកគ្រូស្គាល់វាលរេញអត់?

ដារ៉ា : ស្គាល់ ។

នឿន : គោកដេកឈរនឹង អានឹងដាក់មន្ទីរពេទ្យមួយ ផលិតថ្នាំទៀត អាស្រែចានក៏នៅ លផ្នែកមូលដ្ឋានក៏នៅ ហើយអាកន្លែងវាលរេញក៏នៅ ផលិតថ្នាំបូរាណ ពាក់កណ្ដាលសម័យ ជាងច្នៃប្រឌិតម៉ាស៊ីនសុទ្ធតែគ្រាប់ស៊ុយប្រវត្តិដូចឥឡូវចឹង ។ ជាងសម័យ ដីរីជីកពីភ្នំ ។

ដារ៉ា : ជីកបុសឈើ?

នឿន : ធ្វើត្រឹមត្រូវណាស់ ស្អាត អានឹងវាចូលលក្ខណៈពាក់កណ្ដាលបូរាណ ពាក់កណ្ដាលសម័យ ។

ដាវ៉ី : ពូបានចូលរួមផលិតធ្វើ?

នឿន : ខាងនឹង១ក្នុងកន្លែងខ្ញុំ ប៉ុនខ្ញុំអត់ផលិត ប៉ុនខ្ញុំផលិតនៅខាងផលិតខាងថ្នាំសម័យ ។

ដាវ៉ី : ចុះនៅកោះខ្យងនឹង?

នឿន : បាទ! កន្លែងខ្ញុំនៅកោះខ្យង អាវាលរេញនៅវាលរេញ ប៉ុនកន្លែងទាក់ទងគ្នា កន្លែងតែមួយ មូលដ្ឋាននៅលង្វែក ។ ក្រោមមកបើយើងប្រហែលជាជិតច្រូតស្រូវកំពុងនេះខែ១០នឹងខ្ញុំរៀន ពេទ្យភ្នំពេញ ។

ដាវ៉ី : បានរៀនពេទ្យភ្នំពេញទៀត?

នឿន : បាទ! នៅពេទ្យរុស្ស៊ីនេះ ។

ដាវ៉ី : ខែ១០, ៧៨នឹង ត្រូវទេពូ?

នឿន : បាទ!

ដាវ៉ី : មិនជិតបែកហើយ?

នឿន : មើលទៅឈប់ ទៅកោះខ្យងមិនមែនដល់៧៨ទេ, ៧៧លោកគ្រូ៧៧កន្លែងនោះមិញ ៧៧ យើងធ្វើស្រែខែ៧ ខែ៨នឹង ទៅនៅស្រែចាម ។ និយាយបកមកវិញ ស្រែចានវាលរេញនឹង លង្វែកកន្លែងមូលដ្ឋាននឹង ខ្ញុំទៅនៅនឹង បានដល់ខែមើល៨-៩-១០-១១-១២ បានខ្ញុំមក រៀនពេទ្យនៅពេទ្យរុស្ស៊ី ។

ដាវ៉ី : អាចចូលដើម៧៨?

នឿន : បាទ! ដើម ប្រហែលជាខែ៣ចុះ នៅដើម លោកគ្រូនោះ ។

ដាវ៉ី : វានៅដើម ។

នឿន : បាទ! វានៅដើមអាចខែ៣ ខែ៤ ខែ៥ ខែ៦ ខ្ញុំរៀនតែ៦ខែទេ ។

ដាវ៉ី : សុំសួរថយក្រោយតិច ដែលមាននារីពេទ្យម្នាក់ដែលហៅពូពីកន្លែងភ្លូវស្រែ?

នឿន : បាទ!

ដាវ៉ី : ហើយប្រាប់ថាបងហៅ ទៅកំពង់សោម?

នឿន : ថាបង១ហៅទៅកំពង់សោម ។

ដាវ៉ី : ចុះកាលជិនាន់នឹង បង១ពេលនឹងពូយល់ថាបងនឹងអ្នកណាគេ?

នឿន : បងនឹងមេក្រុមខ្ញុំនឹង ខាងផលិតថ្នាំនឹង បងរី១ ។ គាត់ស្រុកនៅកំពង់ឆ្នាំង យើងហៅស្រុក ១០៧ ប៉ុនឥឡូវដូចស្រុកបរិបូណ៌ ស្រុកអីខ្ញុំភ្លេច ។

ដាវ៉ី : ចុះបងនៅនឹង បងដូចជាអាយុច្រើនដែរហើយចូលដល់?

នឿន ៖ ៧៨, អាយុ១៨ ។

ដារ៉ា ៖ បងមាន?

នឿន ៖ ខ្ញុំមករៀនហើយ ។

ដារ៉ា ៖ នៅលង្វែកនឹង បងមានដឹងមានស្គាល់ពូមីងណា ដែលជាពេទ្យធំ បន្ទាប់ពីឈ្មោះរី បន្ទាប់ពីឈ្មោះរី នឹងប្រធានពេទ្យធំ?

នឿន ៖ គាត់នៅសំឡូតនោះ ។

ដារ៉ា ៖ ឈ្មោះអីគេ?

នឿន ៖ ឈ្មោះបង យ៉ាន ។

ដារ៉ា ៖ យ៉ាន គាត់ស្រីប្រុស?

នឿន ៖ ស្រុកកំណើតគាត់នៅកំពង់ឆ្នាំង ស្រុក១៨ ចុះពីកំពង់ឆ្នាំងទៅក្រោម ។

ដារ៉ា ៖ គាត់គ្រប់គ្រងពេទ្យនៅកន្លែងនឹងទាំងអស់?

នឿន ៖ គាត់ក្រោមដែរ ។

ដារ៉ា ៖ មានពីលើនឹងទៀត?

នឿន ៖ មាន ។

ដារ៉ា ៖ នៅក្នុងពេទ្យកំពង់ឆ្នាំងនៅលង្វែកនឹង ពូដែលឃើញមានគណៈប្រតិភូ ឬអ្នកធំអីគេទៅមើល?

នឿន ៖ មានដែរ ប៉ុន្តែគ្រាន់ថាយើងអត់ចាប់អារម្មណ៍ដល់ ដូចលោកគ្រូជិះឡានទៅដល់នឹងឈប់នឹងចូលសាលា តែយើងការងារយើងចេះធ្វើ ។

ដារ៉ា ៖ តែធ្លាប់ឃើញ?

នឿន ៖ បាទ!

ដារ៉ា ៖ ញឹកញាប់?

នឿន ៖ ញឹកញាប់ដែរ ។

ដារ៉ា ៖ ជាប្រតិភូ ដែលឃើញជាមនុស្ស?

នឿន ៖ ដែល ។

ដារ៉ា ៖ ឃើញជាមនុស្ស អ្នកណាខ្លះ ពូដឹង ឧទាហរណ៍ដូចជា?

នឿន ៖ ស្គាល់អត់អស់ ពិបាកយល់ណាពេលនឹង ។

ដារ៉ា ៖ ចុះស្គាល់នរណាម្នាក់ដែលនៅក្នុងចំណោមគណៈប្រតិភូ ជាអ្នកធំទៅមើលកន្លែងពេទ្យនឹង?

នឿន ៖ អត់ចាំបាន គណៈប្រតិភូ គ្រាន់តែឃើញទៅជាឡាន ។

ដារ៉ា ៖ មានឡានទៅ?

នឿន : បាទ!

ដារ៉ា : ឃើញគណៈប្រតិភូជាមនុស្សដែរ?

នឿន : បាទ!

ដារ៉ា : ស្លៀកពាក់ម៉េច?

នឿន : ស្លៀកពាក់ជា ទៅមានបរទេស ស្លៀកពាក់ជាភ្ញៀវ ។

ដារ៉ា : ពូមកដល់ពេទ្យរុស្ស៊ីថាមករៀនៗផ្នែកអី?

នឿន : ខ្ញុំមកដល់នឹងរៀនខាងផ្នែកសម្ភារៈ ហុចសម្ភារៈវះកាត់ ។

ដារ៉ា : ហុចសម្ភារៈវះកាត់?

នឿន : បាទ! ខាងផ្នែកវះកាត់ ។

ដារ៉ា : គ្រូខ្មែរ គ្រូបរទេស?

នឿន : គ្រូពេលនឹងមានខ្មែរ គ្រូបរទេស ហើយនឹងលោកតាជួន ជឿន ។ លោកគ្រូ ស្គាល់អត់?

ដារ៉ា : ខ្ញុំឮឈ្មោះ គាត់ ។

នឿន : គាត់ទើបនឹងស្លាប់ ។

ដារ៉ា : គាត់ជាពេទ្យធំ?

នឿន : បាទ! ពេទ្យធំ និយាយរួមគាត់ជាបញ្ញវ័ន្តនិស្សិតពីដើមស្រុកបារាំង ។ ប៉ុនគាត់ចេញទៅតស៊ូសង្គ្រាម អ៊ីៗដែលខ្ញុំថានៅមូលដ្ឋានធំនឹង គាត់តាំងពីអើយ ហើយយើងចូលស្រុក៧៥នឹង ។ ហ្នឹងគាត់ចូលមកផ្ទះគាត់ ឡានគាត់នៅភ្នំពេញដដែល ។ ហើយគាត់នៅធ្វើការនៅពេទ្យរុស្ស៊ី ហៅពេទ្យ១៧មេសា គាត់ខាងផ្នែកវះ ផ្នែកជម្ងឺទូទៅ ប៉ុនដល់ពេលជម្ងឺណាគាត់ត្រូវវះដូចវះបេះដូង អានឹងបានគាត់ចូល ។ បើក្រៅពីនឹងគេឲ្យឯកទេសតាមផ្នែកទៅ ។

ដារ៉ា : ពូធ្វើការតាមពេទ្យចល័តរហូតមកពីដើមមក មានពេទ្យជួន ជឿននៅជាមួយ?

នឿន : គាត់នៅមូលដ្ឋាន យើងចង់ទៅរៀនយើងឥឡូវពេទ្យតាកែវ យើងចេញពីមណ្ឌល អង្គរកាស្រុកមណ្ឌល ស្រុកអង្គរការ ឬតាមពេទ្យឃុំអង្គការយើងៗទៅចឹងទៅបញ្ជូនទៅកន្លែងនឹងទៅ ។ ឬក៏យើងត្រូវទៅសិក្សាទៅប្រជុំទៅរៀន ហើយខាងតាកែវថាតម្រូវទៅរៀននៅភ្នំពេញ ទៅប៉ុន្មានរូបៗស្រេចមេចាត់តាំង ពេលនោះគេប្រើពាក្យចាត់តាំង ។

ដារ៉ា : ចុះមកដល់ពេទ្យរុស្ស៊ីនឹង ដែលរៀន៦ខែនឹង បានរៀនផ្ទាល់ជាមួយពេទ្យជួន ជឿនទេ?

នឿន : បាទ! ជួបគាត់រាល់ថ្ងៃ ប៉ុនដល់អាការផាវណាដែលយើងឆ្ងល់យើងសួរគាត់ដូចលោកគ្រូ មានការចំណាប់អារម្មណ៍ខាងអានឹងសួរគាត់ ។

ដារ៉ា : តែគាត់អត់ដែលបានចូលបង្រៀនថ្នាក់ពូ?

នឿន : ចូលដែរ អានឹងមានម៉ោងដូចថាយើងក្មេងៗថ្នាក់ទី១១ ១២ ម៉ោងគណិត ម៉ោងរូប ម៉ោងគីមីទៅ ។

ដារ៉ា : ដល់ម៉ោងណាគាត់ គាត់ចូលបង្រៀនដែរ?

នឿន : បាទ!

ដារ៉ា : ចុះក្រៅពីពេទ្យ ជួន ជឿន មានពេទ្យអី?

នឿន : មានតានីៗ គាត់មកពីបារាំងដែរ ។

ដារ៉ា : អីនី?

នឿន : អត់ចាំត្រកូលលោកគ្រូ ខ្ញុំ ។

ដារ៉ា : ដឹងឈ្មោះពេទ្យនី?

នឿន : បាទ! ហ្នឹងគាត់ចំណាស់ល្មម ពូ ។

ដារ៉ា : ល្មមហៅពូ?

នឿន : បាទ!

ដារ៉ា : ហើយមានពេទ្យអីទៀត?

នឿន : ប្រពន្ធតាជួន ជឿន ។

ដារ៉ា : ឈ្មោះអី?

នឿន : ប្រពន្ធតាជួន ជឿនឈ្មោះអី ហ៊ឺ!ភ្លេចៗប្រពន្ធតា ចាំរាល់ដង ក្រោយមកភ្លេច ។

ដារ៉ា : ប្រពន្ធតាជួន ជឿននឹងក៏ពេទ្យដែរ?

នឿន : អូ! ចំណាប់ ។

ដារ៉ា : គាត់ជំនាញខាងអី?

នឿន : គាត់ផ្នែកបេះដូង ។

ដារ៉ា : ហើយពូថាមានពេទ្យបរទេស?

នឿន : ចិន ។

ដារ៉ា : ចិន?

នឿន : ចិនវៀតណាមអី ពេលនឹងយើងដាក់ទូតគ្នាដែរ ។

ដារ៉ា : ហើយឆ្នាំ៧/៨នឹងដូចចង់ដាច់គ្នា?

នឿន : អានឹងនៅៗ ។

ដារ៉ា : ទំនាក់ទំនងជាមួយវៀតណាម?

នឿន : បាទ!នៅដែរ អត់ទាន់នេះទេ ទូតដកវៀងខួន ។

ដារ៉ា :  ដករៀងខ្លួន តែពេទ្យនៅទេ?

នឿន :  នៅយើងអត់ទាន់ចេញទាំងស្រុងទូត ហើយក៏អាពេលអ្នកនេះនៅខ្លះ ប៉ុនដល់ក្រោយមកមានដូរទូតគេចេញ ការទំនាក់ទំនងមានវគ្គមានឃ្លាទៅ ។

ដារ៉ា :  ចុះពេទ្យរៀននឹង បើសិនជាគ្រូពេទ្យបរទេស ដែលពូថាចិននឹង គេមកបង្រៀនមានអ្នកបកប្រែទេ ឬយ៉ាងម៉េច?

នឿន :  ចិនជួនកាលអ្នកបកៗ គាត់ចេះខ្មែរៗ ។

ដារ៉ា :  ចិននឹងចេះខ្មែរទៀត ពេទ្យនឹង?

នឿន :  បាទ! ប៉ុនគាត់និយាយដែរ គាត់ថា តាជួន ជឿន គាត់និយាយម៉្ង គាត់ថា “បង្រៀនមិនមែន ចេះតែងាយរៀនទេ កុំចេះតែចាប់ កុំចេះតែយកសម្លាប់” គាត់ថាចឹង ពេលប្រជុំពេលអីគាត់ថា ហើយចិនក៏ថាដែរគាត់ថា “ការបង្រៀនឲ្យចេះឲ្យដឹងនេះក៏មិនងាយដែរ មុននឹងបានបង្រៀនបានចេះនេះ មិនមែនចេះតែចេះរឿងពេទ្យនោះមិនងាយទេ” ហើយចឹងប៉ុល ពត ដឹកនាំនឹង កុំចេះយកទៅសម្លាប់ ។ តាជួន ជឿន គាត់អត់ខ្លាចថាទេ ។

ដារ៉ា :  គាត់ចឹង?

នឿន :  បាទ!

ដារ៉ា :  ចុះម៉េចទាក់ទងនឹងរឿងយកទេសម្លាប់នឹង?

នឿន :  ដឹង ដល់ពេលនេះចេះយក ឆ្ងល់ អានឹងនិយាយដល់កន្លែងនឹងមានការយកមិនដឹងយករបៀបម៉េច ខ្ញុំភ័យខ្លាចដែរ រៀនបាន៦ខែ កេះៗសុំមកកន្លែងវិញ ចេញវិញ ។

ដារ៉ា :  ចឹងប្រហែលជាអាចថាមានការបាត់ខ្លួន?

នឿន :  បាត់ៗចឹងម៉្ង ។

ដារ៉ា :  សិក្ខាកាមបាត់អីចឹង ដល់ពេលចឹងតាជួន ជឿននិយាយចឹង?

នឿន :  តាថា គាត់ថា ដល់ចឹងប៉ុលពតថា ខ្ញុំអត់ឮប៉ុលពតថាផ្ទាល់ទេ ប៉ុនដល់ពេលនេះមេខ្លះគាត់ថា តាជួន ជឿនគាត់ថាប៉ុលពតថា អាងឯងនិស្សិត អាងឯងបញ្ញាវ័ន្តនេះ ខ្លាចគេចេះ ។ អត់ងាយបង្រៀនទេ គាត់បង្រៀនតាំងពីសង្គ្រាមក្នុងព្រៃ រហូតមកក្នុងស្រុកបង្រៀនទម្រាំបានចេះដឹង ។ ចុះមនុស្សម៉ាស្រករមុនមិនមែនអ្នកល្ងង់អី ចេញរៀនមកបារាំងអង់គ្លេសរលាយ និយាយពីរៀនជម្ងឺទូទៅវះកាត់តាមផ្នែកវះកាត់ទូទៅអត់មានទាល់ទេ ។ ចឹងទៅគាត់ថា គាត់អត់ មានស្មារតីបង្រៀនទៀតទេ គាត់ថាដល់ចឹងវាហិនហោចអស់ ចិនក៏គេថាដែរ ។

ដារ៉ា :  ចិនថាចឹងដែរ?

នឿន :  បាទ! អាពេលបាត់ខ្លួនអីចុះឡើង វាមិនដឹងចេញមកពីប្រភពណា យើងអត់យល់ការងារគេ ។

ដារ៉ា : ដល់ពេលបាត់ចឹង ចិនក៏ថា តាដួន ជឿនក៏ថាដែរ?

នឿន : ថាៗខ្លាំងណាស់ ។

ដារ៉ា : ចង់និយាយថា ការបណ្តុះបណ្តាលមិនមែនងាយស្រួលទេ?

នឿន : បាទ! អត់ងាយទេ លោកគ្រូ ។

ដារ៉ា : ហើយបើបណ្តុះបណ្តាលបានហើយ ចេះ?

នឿន : ចេះយកទៅដកទៅនេះ ដកទៅនោះ ។

ដារ៉ា : យកទៅសម្លាប់ ចង់និយាយចឹង?

នឿន : បាទ! ចឹងហើយយកទៅសម្លាប់ចោលអីចឹងទៅ ។

ដារ៉ា : មានដឹងតាំងពីពេលនឹងដែរ?

នឿន : ដឹង ប៉ុនយើងអ្នករៀន យើងគ្រាន់ស្តាប់ ។ ពេលនេះដែលតើលោកគ្រូ តាអៀង សារី មិនខាង ក្រសួងការបរទេស យាយអៀង ធីរិទ្ធ មិនប្រពន្ធគាត់ ខាងអី!ផ្នែកសុខា ។

ដារ៉ា : សង្គមកិច្ច?

នឿន : អឺ!សង្គមកិច្ច កន្លែងជ-៥ វត្តភ្នំបៀតវត្តភ្នំ លោកគ្រូដែលចូលមកនឹងទេ កន្លែងនឹងមាន កន្លែងចំលាក់កន្លែងពិសោធន៍ មន្ទីរពិសោធន៍ចំលាក់គ្រោងឆ្អឹងតូចធំនៅនឹង អានឹងគេមាន សប្តាហ៍ដូចថាសៅរ៍អាទិត្យយើងមកនឹង កន្លែងនឹងកន្លែងរូបភាពដាក់ស្តែង ។

ដារ៉ា : អានឹងគេហៅអី អី?

នឿន : ជ-៥ ។

ដារ៉ា : ជ-៥?

នឿន : របស់យាយអៀង ធីរិទ្ធនឹង ។

ដារ៉ា : នៅវត្តភ្នំ?

នឿន : បាទ! បៀតវត្តភ្នំ ខ្ញុំភ្លេចហើយ ពីខាងលិចវត្តភ្នំ ហើយខាងណាជិតនឹង ប៉ុនកន្លែងនឹងពីសង្គម ដើមម៉ង មិនមែនទើបនឹងកើត ។

ដារ៉ា : មានសាលាពេទ្យយើងរាល់ថ្ងៃ?

នឿន : បាទ! បែបដឹងលោកគ្រូ ។

ដារ៉ា : សាលាពេទ្យយើងរាល់ថ្ងៃ?

នឿន : ខ្ញុំទៅថ្ងៃមុនជិតដល់ ខ្ញុំចេះសង្ស័យត្រង់ណាទេ ចេះដើរៗដល់ខាងកើតនឹង វាដូចចំណាំ ។

ដានី : សណ្ឋាគារលើរ៉ូយ៉ាល់ សណ្ឋាគារលើភ្នំ?

ដារ៉ា : លើរ៉ូយ៉ាល់?

នឿន : សង្ស័យក្បែរនឹងដែរនឹងដែរ ខ្ញុំទៅពីពេទ្យរូស្ស៊ីទៅនឹង ។

ដារ៉ា : ពីព្រោះវត្តភ្នំវាខាងកើត វានៅខាងមាត់ទន្លេ បើខាងលិចវាមកខាងសាលាពេទ្យ?

នឿន : បាទ! ក្បែរវត្តភ្នំដែរនឹង ។

ដារ៉ា : បើថាកន្លែងនឹងពូថាជ-៥ ហើយមានគ្រោងឆ្អឹងមានអីដាក់ស្ដែងមានតែសាលាពេទ្យ ។

នឿន : បាទ!

ដារ៉ា : ព្រោះកន្លែងវាគ្មានស្អីក្រៅពីបនឹងមកផង ។

នឿន : ដល់ឥឡូវនៅដាក់ចឹង?

ដារ៉ា : នៅសាលាពេទ្យយើងគេហៅសាលាក្រហមៗ ។

នឿន : ហ្នឹងហើយ ។

ដានី : ជាប់ផ្លូវធំម៉ង?

នឿន : ខ្ញុំមកនឹងញឹកណាស់ ។

ដារ៉ា : ជាប់ផ្លូវធំ?

នឿន : បាទ! ព្រោះអីខ្ញុំរៀនផ្នែកហុចសម្ភារៈវះកាត់ គេហៅជាងពេទ្យទៅចុះ ។

ដារ៉ា : ធម្មតាក្នុងការវះកាត់ ។

នឿន : មានអីទាំងអស់ ។

ដារ៉ា : យើងដុកទ័រចូលមកវះកាត់ទេ អារឿងហុចសម្ភារៈរឿងយើង ។

នឿន : ហើយយើងចំហ៊ុយសម្ភារៈឆ្អិនមិនឆ្អិន ប្រើឆ្នាំងអគ្គីសនីធំៗមិនកើត អានឹងមកពីយើង ។ ចឹងបានខ្ញុំច្បាស់ការងារអស់នឹង ហើយដល់ហើយក្រោយមកទៀត ខ្ញុំចេញមកវិញ ។ ដល់មកវិញខ្ញុំទៅនៅវាលរេញ ។

ដារ៉ា : ចេញពីពេទ្យរូស្ស៊ីដែលថាមករៀននឹង?

នឿន : បាទ! ខ្ញុំខស្បាហ៍ប្រជុំ គេប្រជុំនៅពេទ្យរូស្ស៊ី យាយអៀង ធីរិទ្ធ គាត់មកប្រជុំ គាត់និយាយរឿងចាប់ និយាយរឿងចង និយាយពីរឿងចេះចុះ ខ្ញុំចេះគិតអត់ធ្វើ ។ និយាយរួមលោកគ្រូខ្ញុំស្ដាយណាស់ខ្ញុំស្ដាយ ខ្ញុំកើតមកខ្ញុំអត់បានរៀនចប់ចុងដើមដូចលោកគ្រូ បានសួរពីខាងដើមខ្ញុំស្ដាយអ្នកចេះស្រករមុន បណ្ឌិតដូន ជឿន ដែលលោកបណ្ដុះបណ្ដាលហើយ ស្រករគាត់ក្រោមគាត់បន្ដៗគ្នានឹងលោកគ្រូ ។ បើយើងនិយាយអ្នកប្រាជ្ញមិនធម្មតា ប៉ុនវាចេះបាត់ចុះបាត់ឡើង មិនដឹងរបៀបម៉េច ប្រទេសកម្ពុជាពេលនោះ គឺថាវាយើងអត់យល់ដល់ ខ្ញុំអត់ដឹងដែរ ដល់ចឹង ខ្ញុំស្ដាយ ខ្ញុំដឹងពីស្ដាយ ។

ដារ៉ា : ដល់ពេលចូលមក រៀនសូត្រនៅកន្លែងពេទ្យរូស្ស៊ីនឹង អៀង ធីរិទ្ធ ខស្បាហ៍មកនឹងដែរ?

នឿន ៖ អូ! មកប្រជុំៗ៣ថ្ងៃ។

ដារ៉ា ៖ ប្រជុំរឿងអីខ្លះ?

នឿន ៖ ប្រជុំសំខាន់រឿង អត់មាននិយាយរឿងបច្ចេកទេសទេ និយាយពីរឿងខ្មាំង ថាចឹងម៉ង ព្រោះ អីលោកគ្រូចង់និយាយពីក្នុងរបបនឹង យើងឲ្យស្របនឹង បើអត់និយាយចឹងម៉េចដឹង។

ដារ៉ា ៖ បាទ! វាសំខាន់ដែរកន្លែងនឹង ពូអាចមានចាំសម្តីណាមួយដែលអៀង ធីរិទ្ធ?

នឿន ៖ ចាំៗមិនមែនថាមិនចាំ។

ដារ៉ា ៖ ពូសូត្រម៉ាប្រាវ?

នឿន ៖ ឥឡូវប្រជុំសិក្ខាកាមពេទ្យទាំងអ្នកទៅរៀន និងបុគ្គលិកនៅក្នុងនឹង ធម្មតាកន្លែងសាលាពេល យើងសិក្ខាកាមអង្គុយវាមិនទាបមិនកៅអីមួយៗ ហើយកន្លែងមេអាសនៈមិនខ្ពស់ៗចឹង ហើយ មិនមានតុបួនជ្រុង ហើយមានកៅអីមេអង្គុយហែលៗគ្នាដូចេះ ហើយមិនមានផ្លែ មេក្រូដូច សម្តេចហ៊ុន សែនថ្លែងការណ៍ចឹង។ ពេលនោះនិយាយ អានឹងនិយាយក្នុងឆ្នាំ៧៨ ខែ៨។ ចឹងបានខ្ញុំទៅពីនឹងប្រហែលជាខែ៣ខែអីនឹង។

ដារ៉ា ៖ ហ្នឹងខែ៣ទៅ?

នឿន ៖ បាទ!

ដារ៉ា ៖ ចឹងក្នុងខែ៨ ខែ៩វា៥-៦ខែ?

នឿន ៖ បាទ! ខែ៨នឹងចូល៦ខែ សម្តីគាត់និយាយបានន័យថា អារឿងខ្ញុំចេះឃើញតិចដកទៅនេះ ដកទៅនោះ ខ្ញុំចេះកេះគ្នា យើងអត់ស្រួលទេយើង។

ដារ៉ា ៖ គាត់និយាយថាម៉េច?

នឿន ៖ គាត់និយាយគាត់ថា “សព្វថ្ងៃនេះ បក្សយើងមានមាគ៌ាពិសោធន៍ខុស និងពិសោធន៍ត្រូវ” ចឹង លោកគ្រូបើចង់សួរពីក្នុងរបបនឹង យើងដល់និយាយចឹងបានស្រប “មានពិសោធន៍ខុស និង ពិសោធន៍ត្រូវ”ប្រើលេខទោ “ឧទាហរណ៍កន្លងមក និយាយពីការចាប់ខ្មាំង មានចាប់ខុស មានចាប់ត្រូវ” ដល់ចឹងវីបទាញផ្លែមេក្រូចេញចង្អុលរៀងចំ សុំអព្យាស្រ័យ “ដូចជាក្មួយៗ សិក្ខាកាម បុគ្គលិកទាំងស្រីទាំងប្រុស” ចង្អុលរៀងទំនងណាស់ ចុះអាសន្ទខ្ពស់ចង្អុលវាមិនទីង។

ដារ៉ា ៖ បាទៗ ដូចភ្ជុងកាំភ្លើង។

នឿន ៖ បង្អិលក្បាលមេក្រូចេញ “ឥឡូវបក្សមានមាគ៌ាពិសោធន៍ខុស ពិសោធន៍ត្រូវ ចាប់ពីឆ្នាំ ១៩៨៥មកដល់១៩៧៨ខែ៨ មានចាប់ខុស ចាប់ត្រូវ។ ឥឡូវនេះចាប់ពីឆ្នាំ៧៨ ខែ៨ ឡើងទៅអ្នកណាខុស គឺចាប់អ្នកនោះ” អានឹងគេប្រើម៉េចលោកគ្រូ សក់អាណាក្បាលអានឹង។

ដារ៉ា ៖ សក់អាណាក្បាលអានឹងចឹង។

នឿន : ហើយដល់ចឹងក៏ចាប់ផ្ដើម គាត់និយាយទៀត យើងចេះស្ដាប់ថាតាម ថា “ឥឡូវនេះក្មួយៗ ទាំងអស់ ទាំងប្រុសទាំងស្រី បើសិនពីណាធ្លាប់បម្រើ កា.សេ.បេ សេ.អ៊ី.អា នឹងភ្នាក់ងារអ្វីផ្សេងៗដែល ចូលរួមបំផ្លិចបំផ្លាញក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ឥឡូវកន្លងមកបក្សមានពិសោធន៍ខុស តែចាប់ពី៧៨ឡើងទៅនេះ អ្នកណាធ្វើខុសចាប់អ្នកនោះ តែបើសិនជាក្មួយ ឬមិនយើងទាំងអស់មិនហ៊ានរាយការណ៍ចំពោះមុខអ៊ំ ឬក៏ក្នុងសាលាសូមរាយការណ៍តាមរយៈមេក្រុមឡើងរហូតដល់មកអ៊ំក៏បានដែរ” មានអ្នកភ្លើទៀត រាយការណ៍(សើច) ។

ដារ៉ា : មានអ្នកភ្លើរាយការណ៍?

នឿន : ហ្នឹងហើយ អត់ៗរាយៗការណ៍តាមរយៈចឹង មេរហូតដល់កំពូល គេចាប់ទៅ ។

ដារ៉ា : ប្រជុំនិយាយច្បាស់ចឹង?

នឿន : ហ៎! ច្បាស់លោកគ្រូ ខ្ញុំអត់មានថាលេង មានថ្ងៃត្រូ លោកគ្រូនៅចំពោះមុខនឹង ប៉ុននឹងលោកគ្រូសួរនៅក្នុងរបបខ្ញុំនិយាយចឹង ។ កុំឲ្យមានទោសពៃរ៍ដល់ខ្ញុំទៀត ខ្ញុំអត់ដឹងស្លាប់ចោលកូនខ្ញុំខានបានរៀនហើយ បានអីឲ្យកូនខ្ញុំរៀន ។

ដារ៉ា : អត់ទេ យើងចង់បានសម្ដីពិតៗ ។

នឿន : បាទ!

ដារ៉ា : ដល់ពេលគាត់មកប្រជុំ អៀង ធីរិទ្ធមកប្រជុំមិនដែលនិយាយពីរឿង?

នឿន : អត់និយាយរឿងពេទ្យទេ ។

ដារ៉ា : រឿងពេទ្យរឿងអី?

នឿន : មកនឹងអត់និយាយរឿងពេទ្យ និយាយពីរឿងដូចខ្ញុំថាមិញ ។

ដារ៉ា : ហើយមុខមាំអត់ ដល់ពេលនិយាយកាចក្បាលមេក្រូចេញ?

នឿន : យឺ! ធម្មតាមាឌគេធំដង គេមេហើយរឿងអីថាមិនមាំ ។ តទៅទៀតគាត់ថា “ឥឡូវក្មួយៗបានរាយការណ៍ជាច្រើនមកហើយ” អី!ប្រជុំក្នុងសាលាច្រើនថ្ងៃដែរនឹង រយៈម៉ោអាទិត្យមិនតិចណាព្រឹកឡើងដល់ៗ ល្ងាចឡើងទៅទៀត ។

ដារ៉ា : គាត់ចូលរួមរហូតចឹងដែរ?

នឿន : បាទ! គាត់អ្នកមេសាលានឹងម៉ង រួចហើយគាត់ចាប់ផ្ដើមថា “ក្មួយៗ មិត្តយើងខ្លះដែលបានលះបង់ឈប់ចូលរួមការបំផ្លិចបំផ្លាញហើយ ក៏ចាប់ផ្ដើមមានការរាយការណ៍ដោយស្មោះដូនអ៊ំក៏ដូចជាបក្សយើងទៀតហើយ” គេនៅប្រើបក្សចឹង លោកគ្រូ ។

ដារ៉ា : បក្សដូចអង្គការ?

នឿន : អង្គការនឹងមិនសូវប្រើទេ អង្គការតាមសហករណ៍ ។

ដារ៉ា ៖ ចិនវិញ?

នឿន ៖ បាទ!

ដារ៉ា ៖ នៅក្នុងជួរនឹងគេប្រើបក្ស?

នឿន ៖ បាទ! ដូចនិយាយជាមួយអ្នកធំ យើងអត់ទាន់និយាយសំរាយចិន ។ "ដល់ចិនទៅក៏បានឃើញក្អួយស្មោះត្រង់ មិត្តយើងស្មោះត្រង់" តែសម្រាប់ខ្ញុំៗដឹងកេះគ្នា ខ្ញុំថាអត់ធ្វើពួកស្មោះចុះស្មោះឡើងក្របួចហើយ ។ ដល់ចិនហើយចាប់ផ្ដើមនិយាយចិន ការពិត ដល់ពេលចិនឃើញចាប់បន្តបន្ទាប់ ។ ហើយអាមុននឹងក៏ចាប់ដែរ ប៉ុនដល់ពេលនឹងខ្ញុំថារកខ្មាំងចាប់លែងឃើញហើយ គាត់ថាដែរគាត់ថាចាប់ពីឆ្នាំ១៩៨៥ដល់ឆ្នាំ១៩៧៨ខែ៨ ចាប់ផ្ដើមមានពិសោធន៍ខុស ពិសោធន៍ត្រូវ ខ្ញុំចាប់ពីខែ៨ ៧៨ឡើងទៅគឺអ្នកណាខុសចាប់អ្នកនោះ អ្នកណាហ៊ាន រាយការណ៍ស្មោះត្រង់បក្ស អត់យកទោសពៃរ៍អី ចាំតែអត់តើទៅតែចិនអានឹង ខ្ញុំបានច្បាស់ម៉ង គាត់បង្រៀនពិត ។ ហើយខ្ញុំនឹកឃើញថាអត់យូរទេ ។ ខ្ញុំក្មេង ប៉ុនខ្ញុំនឹកឃើញថាអត់យូរ មេឃត្រជាក់កាលខ្ញុំនៅក្បែរមាត់ ឃើញខ្ញុំដើរជាមួយបងរីៗមេក្រុមខ្ញុំមិញនឹងកាលនៅផលិតថ្នាំថា "បង" ខ្ញុំកាលនឹងភ្លើមាត់ដែរ បើគេយកទៅវៃចោលបែបទៅហើយថា "បងយើងនៅក្បែរសមុទ្រ ភ្នំច្រើន រៀងមេឃខៀវខ្ចី ត្រជាក់ខ្យល់រហៀកៗ យើងធ្វើរបៀបនឹង តិចទៀតមានពីណា មកឆាម៉ាត្រឡប់ទៀត" "ប្អូនឯងម៉េចថាចិន" ខ្ញុំថា "ហ៎!ដូចអត់ស្រួលដូចធ្វើរាល់ថ្ងៃ"ខ្ញុំពីដើម មុន ខ្ញុំធ្លាប់បានរៀនថ្នាក់ទី១ទី២ យើងឥឡូវនេះ ហើយខ្ញុំធ្លាប់នៅវត្តម៉ារយៈដែរមិនចិន ខ្ញុំថា "របបពីមុនៗស្រឡាញ់អ្នកបេះ ពីព្រោះពូខ្ញុំគាត់ធ្វើគ្រូបង្រៀនពីដើមបង្រៀនថ្នាក់ទី៧ ហើយ អ៊ុំខ្ញុំសង្ឃរាជមិនមែនអ្នកនេះអីសុទ្ធអ្នករៀនអ្នកសូត្រច្បាស់លាស់ មិនមែនពូជអ្នកកាប់អ្នក សម្លាប់ណា ហើយដល់ឥឡូវធ្វើម៉េចចិន" គាត់ថា "ប្អូនឯងម៉េចនិយាយចិន" ដល់ពេលដើរបណ្ដើរ មកកន្លែងបណ្ដើរ ខ្ញុំថា "បើបងឯង ហ៊ានរាយការណ៍ប្រាប់មេ បងឯងស្លាប់មុនខ្ញុំ" ។

ដារ៉ា ៖ ទៅចិន?

នឿន ៖ ហ៎! អានឹងយើងអ្នកឆ្លាត "ម៉េចប្អូនឯងថាចិន" "អូ!បងឯងនេះតើ បើដើរជាមួយបងឯងដល់ចិនខ្ញុំបង្វិលឲ្យបងឯងវិញ បងឯងហ៊ានល្អមើលបងឯងមិនស្លាប់ ។ បងឯងឃើញរាល់ថ្ងៃប្រជាជនស្លាប់យ៉ាងម៉េច" ស្លាប់តាមសហករណ៍ ម៉ាជួរព្រៃនប់ វាលរេញៗស្រុកព្រៃនប់នឹងស្លាប់រាប់ពាន់ ។

ដារ៉ា ៖ ខ្ញុំធ្លាប់ចុះទៅស្រាវជ្រាវនៅកោះខ្យង ។

នឿន ៖ បាទ! នឹងកោះខ្យង ។

ដារ៉ា ៖ អាកន្លែងនឹងសាហាវដែលនឹង ។

នឿន ៖ ជិតមាត់សមុទ្រ ។

ដារ៉ា ៖ បាទ! ជិតមាត់សមុទ្រ ឥឡូវទៅជាចំការដំឡូងចំការអី គៀកកន្លែងមាត់សមុទ្រ កន្លែងនឹង ទីតាំងគុកគេនឹង ។

នឿន ៖ បាទ! ដល់ចឹងគាត់អត់ហ៊ាន រហូតដល់ខ្ញុំមករៀនមកអី រៀនមកចឹងជួបគ្នា ក្រោយមកបែក គ្នាក៏ចឹងទៅ ។

ដារ៉ា ៖ គាត់អត់ហ៊ានរាយការណ៍?

នឿន ៖ ដល់ពេលខ្ញុំចេញពីនឹង និយាយត្រឡប់សារឡើងវិញ សាលាខ្ញុំបានស្តាប់រៀននយោបាយ ខ្ញុំ ដឹងថាមិនស្រួល ខ្ញុំដឹងដំណើរនេះអត់ផ្លូវទៅ ច្បាស់ជាចាញ់ខាងណាមួយ នឹកក្នុងចិត្តហើយ និយាយជាមួយបង១ តែហ៊ានរាយការណ៍បងឯងស្លាប់មុនខ្ញុំ ថាគំរាមខ្លះទៅ ហ៊ានរាយ ការណ៍ ព្រោះអីគាត់មេដល់ទៅ២នាក់ វាមិនដែលគេចាប់កូនហើយមេចោល ។ ចឹងគាត់អត់ ហ៊ានដែរ ខ្ញុំចេះជំនុំគ្នាដដែល ៗស្តាយអាណិតខ្មែរ មិនមែនថាទើបមកនិយាយចំពោះមុខ លោកគ្រូថាស្តាយស្រណោះ ទើបភ្ញីភ្នែកថ្ងៃនេះអត់ទេ យល់ដឹងខ្លាំងអារឿងនឹង ប៉ុនមិនដឹង ធ្វើម៉េចពេលនោះដូចព្រះអាទិត្យរះគ្រប់ដែនដី គេចទៅណាក៏ខ្យល់មក គេទៅណាក៏ត្រូវថ្ងៃក្នុង ម្លប់ចេញទៅវិញនៅត្រូវថ្ងៃ ។ ចឹងខ្ញុំចេញមកនៅវាលរេញនឹងបានប្រហែលជាមួយអាទិត្យ ត្រឡប់ពីភ្នំពេញមក គ្រប់៦ខែនៅក្នុងឆ្នាំ៧៨ ។ ហើយក៏ឡានដឹកខ្ញុំមក គ្នាខ្ញុំម៉ាឡានចូលមក សម្រាកនៅលង្វែក មន្ទីរពេទ្យធំនឹងម៉ាយប់ ។

ដារ៉ា ៖ បានមកកន្លែងដើម?

នឿន ៖ បាទ! ហើយបានខ្ញុំចេញពីនឹងមកនៅសៀមរាប នៅរហូតដល់ពេល៧៨ ៧៩ ខែ១២ ។

ដារ៉ា ៖ ៧៩ កងទ័ពវៀតណាមចូលមក?

នឿន ៖ បាទ! ពេលនឹងកងទ័ពវៀតណាម កងទ័ពរណសិរ្សសង្គ្រោះជាតិ ។

ដារ៉ា ៖ មកដល់សៀមរាបនៅក្នុងពេទ្យដដែល?

នឿន ៖ ពេទ្យ១ខេត្តនឹង ។

ដារ៉ា ៖ ពេទ្យខេត្តសៀមរាបនឹង?

នឿន ៖ អូ! រៀបចំសម្ភារៈពេទ្យទាំងអស់ទៀត តែរឿងជាងពេទ្យនឹង (សើច) ។

ដារ៉ា ៖ នៅបានប្រហែលប៉ុន្មានខែ?

នឿន ៖ មកដល់រយៈខ្លីណាស់ មកដល់នឹងមិនបានមួយខែស្រួលផង តែអ្នកគេមកមុនគេបានយូរពួកខ្ញុំ គេមកមុនច្រើន ។ មកនឹងមិនមែនមកនេះ យើងគ្រាន់មកធ្វើពេទ្យ សង្គ្រោះមើល ប្រជាជន

ឈើ ចុះយើងពេទ្យពួកកាកបាទក្រហមដឹងខ្យល់អីវ៉ា ដឹងសម្លាប់ដឹងអីណាដឹងធ្វើឲ្យគេរស់ ។ ប៉ុន យើងស្ងាត់ៗ យើងកេះគ្នាមកថា មកពីខ្វះជីវភាព បានជម្ងឺខ្លះវាមិនអាចជាដាច់ទាំងស្រុង ។

ដារ៉ា : ការហូបចុកអីនៅ បងធ្វើជាពេទ្យជាអីនៅក្នុងក្រុមនឹង ការហូបចុកគ្រប់គ្រាន់ទេ?

នឿន : ហូបនឹងយើងនិយាយទៅវាកណ្ដាល វាមានឆ្ងាញ់មួងម្កាល វាមានល្មម វាមានខ្វះ ។

ដារ៉ា : តែបើធៀបជាមួយប្រជាជនធម្មតា?

នឿន : ធៀបជាមួយប្រជាជនធម្មតា ប្រជាជនកន្លែងណាដែលមេគេស្រួលទៅ អានឹងខ្ញុំនិយាយតិចចុះ ។ ឧទាហរណ៍ថាក្នុងកន្លែងមួយៗ ពេលនោះមេខ្លះក៏មានចិត្តធម៌មេត្តាក៏ការហូបចុកមិនអន់ពេកទេ តែដល់មេខ្លះដូចថាមានផ្ដាច់ការ ខ្វះសុជីវធម៌ ដល់ចឹងធ្វើតាមតម្រូវចិត្តគាត់ គឺថាតម្រូវអង្គការនោះ គាត់ធ្វើតឹងតិចទៅអានឹងហូបខ្វះ ។ អានឹងបើការពិតមិនមែនជាក្បត់ទេ មកពីគាត់យល់ថាធ្វើចឹងវាសម បើអ្នកគេមានធម៌មេត្តា គេធ្លាប់បួសរៀន គេចេះដឹងគេលាក់ក្នុងចិត្តគេថា ហូបបន្តិចទៅ បានសមរម្យទៅ ពីលើណាគេដឹងថាយើងស្លសាប់គោថ្ងៃនេះ បើគ្នា យើងអត់មានរាយការណ៍ផង ម៉ាកន្លែងធំនឹង បាទ!វាចឹង ។ ដល់ពេលក្រោយមក បានខ្ញុំ ចេញពីក្នុងសៀមរាបមកនៅ ចេញមកព្រំដែនមកនៅដងរែកនឹងនៅធ្វើពេទ្យទៀតហើយ ។

ដារ៉ា : ក្រោយ៧៩ ហើយនឹង?

នឿន : បាទ! អានឹងអារញ៉េរញ៉ៃពេញទឹកពេញដី មកនៅភ្នំដងរែង មកនៅបង្កើតពេទ្យនៅក្រោមដងរែក គេហៅទឹកចេញៗ ។

ដារ៉ា : នៅលើខ្នងភ្នំប្រាសាទព្រះវិហារ?

នឿន : អត់ទេ ងាវមកត្បូង ។

ដានី : ភ្នំទឹកចេញ?

នឿន : កន្លែងទឹកចេញក្រោមដងរែក ខាងត្បូងបន្ទាយឆ្មារ លោកគ្រូស្គាល់ស្រុករំដួលទេ ម៉ាដូរនឹង ។

ដារ៉ា : ខ្ញុំធ្លាប់ទៅដល់ប្រាសាទបន្ទាយឆ្មារ?

នឿន : បន្ទាយឆ្មារ ខាងត្បូងបន្ទាយឆ្មារនឹង បន្ទាយឆ្មារមិនទាក់ទងពីក្រោមចឹងមកបានដល់បន្ទាយឆ្មារមកត្បូងបេះមក អានឹងស្រុកអំពិល ។

ដារ៉ា : ស្រុកអំពិល ។

នឿន : បាទ! ទំនប់ស្រុកអំពិល លោកគ្រូដែលដល់ បើមិនដែលដល់ ក៏ដែលឮ

ដារ៉ា : ធ្លាប់ឮ ។

នឿន : ហ្នឹងខ្ញុំមកស្នាក់នៅ ខ្ញុំនឹងធ្វើមន្ទីរពេទ្យនៅក្រោមទឹកចេញ ពេទ្យចល័តទៀត ។

ដារ៉ា ៖ ពេទ្យចល័តទៀត?

នឿន ៖ បំបែកគ្នាគ្រប់ពេទ្យធំបំបែកច្រើនកន្លែង ។

ដារ៉ា ៖ នៅក្នុងចន្លោមដែលពួកខ្មែរក្រហមដដែល?

នឿន ៖ បាទ! នៅនឹង អានឹងនៅនឹងត្រង់នឹងទៀតហើយ ចុះពេលនឹងត្រឡប់ទៅវិញទៀត ។

ដារ៉ា ៖ ត្រឡប់ទៅដើមវិញ?

នឿន ៖ បាទ! ហ្នឹងឡប់ទៅវិញ ដល់ពេលត្រឡប់ទៅចឹងក៏ខ្ញុំធ្វើពេទ្យរហូតធ្វើបណ្ដើរៗ គេវល់បាញ់គ្នា អាមែនទែនខ្មែរនិងខ្មែរទំនាស់គ្នាបាញ់គ្នា ។

ដារ៉ា ៖ បាញ់អ្នកខាង?

នឿន ៖ បាញ់គ្នាស្ដាយតែប្រដាប់ពេទ្យទៅទៀត គ្នាខ្ញុំ រួចទៅដល់ធ្វើពេទ្យទៀតទៅនៅម៉ាជួរគេហៅភូមិដូង ម៉ាជួរម៉ាឡៃ ម៉ាជួរខាងលិចម៉ាឡៃខ្សែម៉ាឡៃ ។

ដារ៉ា ៖ តែខ្ញុំអត់ទាន់ទៅដល់ទេ ម៉ាឡៃនឹង ។

នឿន ៖ បាទ! ...ដល់ម៉ាឡៃនឹងដល់មកត្បូងចឹងទៀតមក ស្គាល់លោក អ៊ី ឈាន ដែលឮអត់?

ដារ៉ា ៖ អភិបាលខេត្តប៉ៃលិន?

នឿន ៖ បាទ! លោកអ៊ី ឈានប៉ៃលិននឹង លោកអ៊ី ឈានពីមុនមិនមែននៅប៉ៃលិនទេ លោកខាងបក្សបញ្ចូនក្នុងរដ្ឋកម្ពុជាប្រជាធិបតេយ្យត្រឡប់ក្រោយតិចសិនមកនៅទទួលក្រសួងការបរទេសនៅព្រលានសៀមរាប ។ ដល់ពេលរញ៉េរញ៉ៃគ្នាគាត់ប្រហែល១០នាក់ទេ ឡានតូចឡានធំបរទៅមកទៅអាខ្វះក្រឡាប់បះជើងដូចអណ្ដើកផ្ងារពោះ ចេះទៅរហូតៗមកដល់ម៉ាឡៃ ស៊ីសាផុនឆ្លងប៉ោយប៉ែតខាងត្បូង ។ ដល់ពេលមកដល់ម៉ាឡៃនឹងមក ក្រោយមកកង៍ទ័ពមកពីកងពលទី១ពីមុនកាលទៅច្បាំងនៅក្រចេះ រតនគីរីអឺ!ខាងក្រចេះ ។ ដល់ពេលចឹងហើយបាន ពេលនឹងយើងមិនខ្វះបាយហូប ហើយគាត់មិននៅប៉ៃលិននេះ បានថ្នាក់លើគេហៅថ្នាក់លើៗ ប្រគល់ឲ្យលោកអ៊ី ឈាន គ្រប់គ្រងកង៍ទ័ពនឹងៗដោះស្រាយសេដ្ឋកិច្ច កង៍ទ័ពម៉ាកងពលនៅឈរជើងរហូតទល់យើងចរចាគ្នាក្រោយពី៩៣ ប៉ារីស ហ្នឹង៩១, ២៣ តុលា ប៉ារីសនឹង ។ ហើយក៏លោក អ៊ី ឈាននៅគ្រប់គ្រងទៅ ពេលពួកខ្ញុំមកនៅនឹងទៀតហើយ ។ ប៉ុន្ដែខ្ញុំអត់បាននៅនេះទេ ខ្ញុំមកនៅក្រោយទេ ដល់មកនៅក្រោយអ្នកគេមក មុនគេបាននៅបម្រើការងារនឹងគេវះរបួសគេ មើលអ្នកឈឺអ្នកអីចឹង ។ ខ្ញុំទៅបានម៉ារយៈ ដល់មកវិញដល់មកវិញខ្ញុំក៏មកនៅសំឡូតនៅ នឹងៗម៉ង ។

ដារ៉ា ៖ ដល់បែកក្រោយ?

នឿន ៖ នៅសំឡូតនឹងរហូតទៅដល់ពេលដែលធ្វើពេទ្យនៅសំឡូត ខ្ញុំនៅកន្លែងវះកាត់ ។

ដារ៉ា ៖ គិតមកដល់ភូមិនេះនៅថ្ងៃណាឆ្នាំណា?

នឿន ៖ ដល់ពេលនៅសំឡូតចឹងនៅបានយូរ ដល់ពេលឆ្នាំ៩០ប៉ុន្មាន៩០គត់ៗ ខ្ញុំចេញពីមន្ទីរពេទ្យសំឡូត ខ្ញុំទៅជំរំអន្តរជាតិចិញ្ចឹម ។

ដារ៉ា ៖ ជំរំមួយទៀត?

នឿន ៖ បាទ!

ដារ៉ា ៖ ជំរំអីគេ?

នឿន ៖ ជំរំសាយខេ ។

ដារ៉ា ៖ សាយខេ?

នឿន ៖ សាយខេ ខ្វះគេនៅសាយអេច តាង៉ុកៗណា សាយអេច សាយខេ ជំរំធំៗខាងអ៊ីដាង ស្បែកខ្ញុំអនឹង បងប្អូនញាតិមិត្តហៅទៅអាមេរិច កាណាដា អត់ទៅបងប្អូនចាស់ៗថា អឺ!ឯងកុំទៅ ចោលអញ ។ ដល់ពេលនេះ ខ្ញុំនិយាយនេះរំលង ខ្ញុំចូលជំរំស្រះកែវម្តង ។

ដារ៉ា ៖ ជំរំស្រះកែវ?

នឿន ៖ កាលខ្ញុំនៅឆ្លងម៉ាឡៃ ស៊ីសាផុន ប៉ោយប៉ែត ភូមិដូងភូមិអីមិញនឹង ចូលជំរំស្រះកែវឆ្នាំ៧៩ ខែដើមឆ្នាំ ខែ៣ ខែ៤ រហូតដល់៧០ ។

ដារ៉ា ៖ អាពេលរត់?

នឿន ៖ ដល់ឆ្នាំ៨០ខែ៤មកវិញ ទៅបានម៉ាឆ្នាំ ។ ចាស់ៗនៅមិនសុខ កេះៗគ្នាមកទៀតហើយ មករហែមរហាមម៉ាជួរម៉ាឡៃ ស៊ីសាផុន ធ្វើប្រជាជនម៉ាចំអែតធំ ហើយបានខ្ញុំមកនៅប៉ៃលិនមក ប៉ៃលិនបានខ្ញុំមកសំឡូត ចេញពីសំឡូតមកជំរំសាយខេវិញ ចេញពីសាយខេ ខ្ញុំមកស្រុកអន្តរជាតិដឹក ។

ដារ៉ា ៖ ពូទើបចូលពេលមាតុភូមិនិវត្តន៍?

នឿន ៖ បាទ! ចូលមាតុភូមិនិវត្តន៍ ភូមិនេះខ្ញុំទិញដីក្រហែងក្រហូងកន្លែងនឹងសុទ្ធតែខ្សែកាញ់គេបាញ់គ្នា អត់មានអីទេ ខ្ញុំដាំតើអានឹង ។ ខ្ញុំនឹកចេះទេ លោកគ្រូអើយ ម្តាយដើររកកូនពេលស្លាប់ទៅនៅឪពុកទេ ប្អូនពៅប្រុសមួយអាយុ១០-១២ឆ្នាំនៅចេះថៃទៅ ។ ឪពុកស្លាប់ទៅ នៅប្អូនខ្ញុំការឲ្យនៅរាល់ថ្ងៃខាងលិចសាលា បានកូនមួយហើយ ។ ហើយខ្ញុំក៏នឹកឃើញថា អាត្មាខ្ញុំមុជមិនជ្រៅទៅមិនឆ្ងាយ ស្បែកកម្ពុចឹង នឹកឃើញថាបើបាននៅចឹងនៅជិតសាលានេះ ក៏ទិញដីគេនៅទៅគ្មានលុយណាទេ ចេះតែដោះស្រាយបានតិចតួចដែលកាកបាទលោកជួយណា៎ ។ ហើយដល់ ពេលចូលមកចឹងទៅក៏ចាប់ផ្តើមកសាងកន្លែងនឹង ឲ្យកូនរៀនជិតសាលាផ្ទះ ។ ហើយខ្ញុំវាមិនច្បាស់ដូចលោកគ្រូបានសាកសួរដំណើររឿងមិញនឹង វាចេះវាចុះៗចង់ឲ្យកូន

រៀនចាប់ពីអាទី១ ឡើងឲ្យទៅដល់អាទីលើទៅ ។ ក្នុងសាលានៅកម្ពុជាយើងរៀនអី កូនឯងរៀនពីត្រឹមទី១ រហូតដល់ទីដែលកូនឯងឈប់រៀនទៅចង់ចឹងទេ រាល់ថ្ងៃហ្នឹងនោះព្រោះអីនឹកឃើញថាកាលពូខ្ញុំ គាត់បានធ្វើគ្រូធ្វើអីនឹកឃើញស្ដាយ ។

ដារ៉ា ៖ ចុះពូចូលមក ចូលពេលដែលគេជំនាន់UN ?

នឿន ៖ បាទ! ចូលមាតុភូមិនិវត្តន៍ UNនឹង ។

ដារ៉ា ៖ UNមាតុភូមិនិវត្តន៍ ជនភៀសខ្លួនមកនឹង?

នឿន ៖ មក ដឹកមកម្ដងតិចៗ មកតាមផ្លូវច្បាប់ត្រឹមត្រូវអត់មានលួចរត់ទៅនេះទៅនោះ ។ យើងមកដល់នេះខ្វះរករឿង ខ្ញុំថានែក!និយាយឲ្យស្រួលបួលកុំខ្មៀល សុទ្ធតែពួកខ្ញុំអាពត អាក្រហមថាពួកឯងគ្រប់គ្នា បានយកពួកខ្មែរក្រហមបានស្រួលៗបេះនោះ ផាប់ហើយអត់ដីឲ្យគេនៅ គេនៅនោះគេមានដីនៅទៅ សម្រាប់ខ្ញុំកាកបាទ UNHCR ចឹងលោកគ្រូ ។ ដឹកចូលមកធ្វើច្បាប់តាំងពីដំរីសាយខេ ច្បាប់ចូលចេញពីស្រុកថៃដល់ប៉ោយប៉ែត ច្បាប់ទៀត រហូតមកដល់លោកគ្រូស្គាល់កប់ស្រូវ នេះអត់?

ដារ៉ា ៖ កប់ស្រូវស្គាល់ ។

នឿន ៖ អឺ!កន្លែងមណ្ឌលស្នាក់នឹង ចេញមកអាផ្លូវយើងខាងជើងជម្ពូវ័ន្តនឹង ដឹកសុទ្ធឡានក្រុងគេនោះមកយើងចុះនៅអង្គតាសោមនេះ ។ មកដល់សួរចង់ទៅឃុំណា នៅកន្លែងណាមកតាមលេខរៀងមក លោកមេស្រុក លោកមេឃុំ លោកមេភូមិ ចៅហ្វាយខេត្តទទួលដឹងព្រួទៅ ។ ហើយមកដល់ស្រុកនេះ ខ្ញុំនៅបានម៉ារយៈ ៧គ្រួសារនៅភូមិត្រពាំងឈូកនេះ ដាក់ជនមាតុភូមិនិវត្តន៍ ។ ហើយពេលដល់ថ្ងៃមួយ គេហៅទៅប្រជុំ ឆ្ងល់ខ្ញុំដើរទៅ ដល់ឆ្នាំ៩០ប៉ុន្មាន អឺ!ជិតបោះឆ្នោត៩៣ ស្រាប់អង្គការជប៉ុននឹង ក្នាគាត់៧នាក់ នារីបកប្រែម្នាក់រៀងល្អិតស្អាតទៀតសស្គុះ ។ ដល់ពេលអ្នក៧គ្រួសារ គាត់មិនសាកសួរគ្រួសារ៦គ្រួសារល្អិតល្អន់ ស្រាប់ចាប់ចំណុចមួយជាមួយខ្ញុំ សួរខ្ញុំផ្ទះនៅណា ។ បងអើយបង ខ្ញុំអត់មានផ្ទះទេ លោកគ្រូ ខ្ញុំកូនខ្ទមតូចនៅនោះ ហើយមិនមានបេះលោកគ្រូ ឃើញអស់សំណើច ក្រឡុកក្រហូងក្រហូងចុះកន្លែងគេបាញ់សន្ត្រាមនោះ ។ មានរឿងអី ហើយខ្ញុំធ្វើល្មមខែប៉ុននឹង ហើយដាក់ដំបូងបន្ទុកឈើវែងទៅបេះៗអាការំម៉ារ៉ាធំដាក់ជ្រែងជើង បេះថតតាំងពីព្រឹក ហាវបាយជិតផាប់ម៉ោងមួយបេះសួរខ្ញុំ សួរប្រវត្តិខ្ញុំមុនដូចលោកគ្រូ ចូលជំរំចេញពីជំរំ តើមានគោលបំណងយ៉ាងម៉េចៗហើយមកដល់ស្រុកយើងយ៉ាងម៉េចៗ ចុះបើសិនក្រោយអន្តរជាតិចិញ្ចឹម១២ខែនឹងតើបានទឹកដីពីណា ។ ខ្ញុំថាលោកគ្រូ បេះខាង អន្តរជាតិមុននឹងដឹកមកទំនាក់ទំនងជាមួយអ្នកដឹកនាំកម្ពុជាច្បាស់ បើសិនជាឈាមជ័រខ្មែរដូចគ្នា លោកអនុញ្ញាតឲ្យដឹកមកហើយ លោកច្បាស់

ជាមិនឲ្យស្លាប់ទេ។ ហើយបើសិនជាលោកអត់ ជួយខបត្ថម្ភឲ្យហូបចុកខ្វះ លោកគ្រូដឹងហើយ ១២ខែលែងឲ្យហើយ អានឹងលោកគ្រូឯងមិន ទាន់ដោះស្រាយបានផង លុប១២ខែចោលឲ្យ ប្រជាពលរដ្ឋដែលយកមកស្លាប់ នឹងលោកគ្រូ ឯងគិតធ្វើម៉េចខាងកាកបាទធ្វើមុខម៉េច ពីដើម ទីមកជួយ ដល់នេះទំនាក់ទំនងជាមួយមេកម្ពុជា ឲ្យបានច្បាស់លាស់។ ប៉ុនថាអ្នកដឹកនាំកម្ពុជា មិនជិតដាច់ទេដល់ចឹងសួរទៅបោះឆ្នោតអត់ ដល់ថ្ងៃបោះឆ្នោតគេសួរទៀត ហើយហេវបាយ ចង់ងាប់ហើយលោកគ្រូកាលជំនាន់នឹង ហើយមានអី៦គ្រួសារមិនសួរ មកសួរតែខ្ញុំដាក់ឡាន។ ខ្ញុំមកសួរ ពេលមកបោះឆ្នោត យកឡានមកប៉ូលីសឡានមួយៗ ពួកនឹងអូ!ប៉ិចនឿនងាប់ ហើយប៉ុននេះ។ ទៅដល់គេសម្ភាសន៍កាំម៉ារ៉ាធំសួរទៀត គេឲ្យខ្ញុំដើរកាយវិការដីប្រហែល ២០០ម៉ែត្រ ដើរគេថត សួរពេលបោះឆ្នោតឲ្យលោកណា?

ដារ៉ា ៖ សួរចឹង?

នឿន ៖ ខ្ញុំថាឥឡូវចេះណាលោកគ្រូ ខ្ញុំជម្រាបជូនបាន ឧទាហរណ៍ថាមនុស្សដែលដើរថ្ងៃក្តៅកំពុងតែ ស្រេចទឹកៗមួយកែវចរណៃ ដឹថ្វាត្រជាក់អ្នកណាក៏ស្រឡាញ់ទឹកនឹងដែរ ក្នុងចំណោមអ្នកដើរ ហត់មែន លោកគ្រូៗ ចឹងពេលនោះបោះឆ្នោត ខ្ញុំប្រៀបចេះ ខ្ញុំបោះឲ្យលោកណា ដែល លោកគ្រប់គ្រងប្រជាជន១០លាននាក់ជាងនោះ។ លោកណាដែលមានសមត្ថភាពគ្រប់គ្រង ពេលនឹងបើលោកណាជាប់លោកនឹងហើយ ទៅប្រាប់ត្រង់ធ្វើអី។ ខ្ញុំថាលោកហាជាប់ហា ជាប់ៗ ដូចឥឡូវលោកគ្រូថតខ្ញុំជាប់ ដល់ពេលជាប់យកទៅ លោកគ្រូទៅបើកមើលខ្ញុំ គេ មិនលបមួលស្លឹកត្រចៀកម៉េច បើគ្រួសារគ្នា៣-៤នាក់ ចឹងខ្ញុំមិនអាចជម្រាបបាន។ ដល់គេ សម្ភាសន៍បោះឆ្នោត ចុះពីឡានលីកាំម៉ារ៉ាចូល...។

ដារ៉ា ៖ ចូលបន្ទប់បោះឆ្នោតថតទៀត?

នឿន ៖ បាទ! ដល់ពេលនឹងគាត់ងៀកទៅនោះ ខ្ញុំចូលគូសហើយ ខ្ញុំចេញ សួរបោះឲ្យអ្នកណា? ថា មិនអាចជម្រាបជូនលោកបានទេ នៅអត់ វាថាបើសិនប្រាប់ជូន៤០ដុល្លាចាយ។ ៤០ជំនាន់ នឹង ១០០ដូរបាន១៥ម៉ឺនរៀល។ មិនបាច់ក៏បានដែរលោកគ្រូ ខ្ញុំអត់ទាមទារ។

ដារ៉ា ៖ ចុះមានឲ្យលុយទៀត?

ដានី ៖ ក្រុមណា?

នឿន ៖ ខាងជប៉ុន ចង់ច្បាស់ម៉ង គេចង់សាកយើង។

ដារ៉ា ៖ ចង់ដឹងយើងមកពីជំរំ?

នឿន ៖ ហើយពេលនឹងមិនមែនចេះសម្ភាសន៍សួរស្រេចចិត្ត នគរបាលរបស់រដ្ឋកម្ពុជាជំនាន់នឹងអត់បាន នៅកៀកនឹង ហើយខ្ញុំចាំតែល្ងង់និយាយតើ ខ្ញុំនិយាយមានទៅប៉ះអ្នកណានិយាយទៅស្អាត

រហូត ។ ហើយដល់ចឹងទៅអត់នេះដល់ពេលបោះៗហើយមកវិញ ខ្ញុំនៅនឹងរហូត ចេះរស់ឲ្យកូនរៀន ។

ដារ៉ា ៖ ឥឡូវកូនដល់មហាវិទ្យាល័យចង់ចប់អស់ហើយ ចប់?

នឿន ៖ ហ៊ឺ! ទើបឆ្នាំទី១ វារវល់ប្រឡង១២ឌុប ហ៊ឺ!ឌុបទី៩ម្តង ។

ដានី ៖ បងប្អូនរៀនឆ្នាំទី១ដូចគ្នា?

នឿន ៖ តែ២នាក់នឹង ។

ដារ៉ា ៖ ប្រុសស្រី?

នឿន ៖ ប្រុសៗ ស្រីមួយទៅរៀននេះពៅ ។

ដារ៉ា ៖ តែ៣នាក់នឹងទេកូន?

នឿន ៖ ៤ ។

ដារ៉ា ៖ នៅសល់មួយទៀត?

នឿន ៖ មួយទៀត ទៅរៀនល្ងាចបានមក ។

ដានី ៖ ប្រុស៣ ស្រី១?

នឿន ៖ ប្រុស៣ ក៏ត្រូវមួយដែរ ស្លាប់បងមួយអាយុ៦ឆ្នាំ ឆ្កែខាំម៉ែវានាំចុះផ្ញូតទឹកស្លាប់ ខ្ញុំវាអត់នៅ ៧៨ អឺ!៨៨ ហើយដល់ហើយក៏ចេះរស់នៅ ចឹងរហូត អ្នកនៅក្នុងស្រុកក្នុងភូមិចេះរករឿង ចេះចុះ ថាចេះរករឿងៗម៉េច ។

ដារ៉ា ៖ តែឥឡូវអត់អី សុខសប្បាយ?

នឿន ៖ ឥឡូវនឹងអត់អីទេ ។

ដារ៉ា ៖ ភូមិពូហើយ?

នឿន ៖ បាទ! ខ្ញុំថាអ្នកខ្លះអត់ស្គាល់ខ្ញុំ អីចឹង ។

ដារ៉ា ៖ ពូត្រឡប់មកស្រុកភូមិពូវិញ?

នឿន ៖ បាទ! និយាយពីព្រំដែន លោកគ្រូ ត្រឡប់ចុះត្រឡប់ឡើងមកស្រុកក៏ចឹង ខ្ញុំមិនដែលមានរករឿងអ្នកណា ជម្រាបត្រង់ដូចថាជម្រាបការងារ ។ តែខ្ញុំទៅនៅព្រំដែន ខ្ញុំបានរៀនវះកាត់នឹងបានក្រោយ៧៩នឹងទៅ ។

ដារ៉ា ៖ ធម្មតាទេ ពូបែកពីស្រុកយូរហើយ ទៅនៅនឹងយូរដល់ពេលចូលមកដល់ស្រុកវិញ អ្នកស្រុកគេឆ្ងល់ថាយើងទៅនៅធ្វើស្អី យើងមកពី ទម្រាំយល់គ្នាបាន?

នឿន ៖ ហើយខ្ញុំអត់មាន រាល់ថ្ងៃខ្ញុំបើកវិទ្យុស្តាប់ ខ្ញុំស្តាប់តែធម៌លោកទេស ហើយនឹងអ្នកអប់រំ ។

ដារ៉ា ៖ ខ្ញុំចាប់អារម្មណ៍កន្លែងមួយ ពូនិយាយថា អីរបស់លោកពូដែលធ្វើសង្គ្រាជ?

នឿន ៖ បាទ! នៅអន្លង់វែង ។

ដារ៉ា ៖ ឈ្មោះអីគេពូ?

នឿន ៖ តា ខៀវ នៅ ។ គាត់មកលេងនឹងរាល់ដង ។

ដារ៉ា ៖ តា ខៀវ នៅ?

នឿន ៖ បាទ!

ដានី ៖ គាត់ធ្វើសង្ឃរាជ ម៉េចបានទៅនៅដល់អន្លង់វែង?

នឿន ៖ អត់ទេ ដែលសង្ឃរាជពីមុនដល់យើងឆ្នាំ៧៥ ពេលនឹងបានមិនបោះមិនៗ ។

ដារ៉ា ៖ ចូលខ្មែរក្រហម?

នឿន ៖ បាទ!

ដារ៉ា ៖ ចូលរបបកម្ពុជាប្រជាធិបតេយ្យ?

នឿន ៖ បាទ!

ដារ៉ា ៖ គាត់ធ្វើសង្ឃរាជនៅវត្តណា?

នឿន ៖ នៅវត្តនឹង ត្រពាំងធំនឹង ។

ដារ៉ា ៖ វត្តត្រពាំងធំយើងនឹង?

នឿន ៖ បាទ! ប៉ុនគាត់បួសហើយ គាត់ទៅរៀននៅវត្តមហាមន្រ្តីនៅភ្នំពេញ ក្រោយមករដ្ឋប្រហារ ក៏គាត់មកនៅសង្ឃរាជវិញរហូត ។ កាលពីមុនក៏នៅវត្តនឹង ក្រោយមកក៏នៅនឹង ៧៥សឹកអស់ចប់ ។ គាត់ចេះរស់ៗទៅ ហើយដល់ពេលគាត់រត់នឹងគេនឹងឯង នៅជិរំ ប៉ុនគាត់នៅខាងអន្លង់វែងរាល់ថ្ងៃ ។

ដារ៉ា ៖ ឥឡូវគាត់ទៅនៅខាងអន្លង់វែង?

នឿន ៖ គាត់ធ្វើអាចារ្យរាល់ថ្ងៃ ។

ដារ៉ា ៖ អាចារ្យ?

នឿន ៖ អាចារ្យការ អាចារ្យបុណ្យ ។

ដានី ៖ លោកពូកាលពីដំបូងលោកពូថាទៅខាងប៉ៃលិនទេ?

នឿន ៖ បាទ! ទៅនឹងខ្ញុំទៅខ្វី លោកអ៊ី ឈានគ្រប់គ្រងកន្លែងនឹង ដោះស្រាយកង៏ទ័ពខ្ញុំខាងកងទ័ពម៉ាកងពលមកពីក្រចេះនឹង ដែលពួកពេទ្យអ្នកគេនៅមុនៗ ដល់ខ្ញុំទៅនៅបានប្រហែលជាប៉ុន្មានខែក៏ខ្ញុំមកសំឡូតវិញ ។

ដានី ៖ ម៉េចបានពូមកសំឡូត?

នឿន ៖ ដែលគ្នាខ្ញុំកាលនឹងខ្មែរយើងកាលនោះជម្រាបត្រង់បក្ខពួក ។ ដល់ចឹងនាំសម្លាប់គ្នា យើងខ្ជិល បបួលគ្នា ហើយលោកអ៊ី ឈាន មិនឲ្យមកទេ ។

ដានី ៖ ពូមានបងប្អូននៅសំឡូតបានមក?

នឿន ៖ បងប្អូនជំនាន់នឹង អាយើងធ្លាប់ស្គាល់គ្នា ចេះមក ការពិតយើងអត់ស្គាល់សំឡូត ប៉ុនមានគ្នា ទៅមកស្គាល់ យើងទៅ ។

ដានី ៖ ដូចខាងប៉ៃលិនយើងខាងខ្មែរក្រហមគ្រប់គ្រងដែរ?

នឿន ៖ បាទ!

ដានី ៖ ខាងសំឡូតខ្មែរក្រហម?

នឿន ៖ បាទ! ដូចគ្នា ។

ដានី ៖ ខាងនឹងយ៉ាងម៉េចដែរនៅខាង?

ដារ៉ា ៖ តែ២បក្សខុសគ្នា?

នឿន ៖ អឺ! លោកគ្រូអើយ វាដូចថាមិញ ដូចខ្ញុំជម្រាបលោកគ្រូខាងដើម ដល់កាលយើងមហា លោតផ្លោះ មហាអស្ចារ្យកន្លែងណាគេមានចិត្តធម៌មេត្តាមានឆ្ងាញ់មានឆ្អែត កន្លែងណាចិត្តមិន សូវល្អក៏អត់ឆ្អែតទៅ អានឹងក្នុងលក្ខណៈវាចឹង ។ ដល់ចឹងទៅចង់រករឿងគ្នាឯង គេថាដីរដល់ គ្នា វាស្រមោចសន្ធរវាពិបាកអីចឹង ។

ដារ៉ា ៖ ខ្ញុំចង់សួរបកក្រោយពូតែមួយទេ ។ ចាប់អារម្មណ៍រឿងអៀង ធីរិទ្ធ ពូមិនធ្លាប់ឃើញអៀង ធីរិទ្ធមកប្រជុំនៅពេទ្យរុស្ស៊ី ពេលដែលពូមករៀនពេទ្យ?

នឿន ៖ បាទ!

ដារ៉ា ៖ ចុះកាលពូនៅពេទ្យនៅមូលដ្ឋានធំនៅលង្វែក ដែលឃើញអៀង ធីរិទ្ធទៅនៅ?

នឿន ៖ ឃើញឡានៗប៉ុនមិនដឹងខាងណា ។

ដារ៉ា ៖ ដល់ពេលពូស្គាល់ពេល?

នឿន ៖ បាទ! ស្គាល់ពេលខ្ញុំមករៀនៗចូលក្នុងសាលាតែម្តង ។

ដារ៉ា ៖ ច្បាស់ម៉ង អៀង ធីរិទ្ធនឹង?

នឿន ៖ ច្បាស់ណាស់ ពន្យល់ទល់មុខចឹងរឿងអីមិនច្បាស់ បង្រៀនម៉ាអាទិត្យអានឹងព្រឹកល្ងាចៗ ។

ដានី ៖ ចុះពូកាលមកពីប៉ៃលិនមកសំឡូតមកឆ្នាំណា?

នឿន ៖ ឆ្នាំអឺ! ឆ្នាំ៨១ ។

ដានី ៖ ឆ្នាំ៨១ កាលនឹងដូចថាពូមានទំនាស់អីនៅខាង?

នឿន ៖ អត់ទេ អត់មានៗ ប៉ុនដល់ជំនាន់នឹងយើងដឹងថាមានគ្នាធ្លាប់ស្គាល់ក៏សុំមេ មកសំឡូតធ្វើពេទ្យទៀតទៅតែបឹង ។

ដានី ៖ នៅសំឡូតនឹងដូចគេមានអគ្គភាពយ៉ាងម៉េចទៅ?

នឿន ៖ មាន អគ្គភាព អានឹងគេចែកតាមតំបន់គេ ប្រកៗគេ ។

ដានី ៖ គេហៅអីគេនៅសំឡូតនឹង ដូចថានៅខាងប៉ៃលិន អ៊ី ឈាន គាត់អ្នកគ្រប់គ្រងខាងកងពល?

នឿន ៖ គាម៉េត ដឹងស៊ូម៉េតទេ ។

ដារ៉ា ៖ ស៊ូ ម៉េត?

នឿន ៖ ស្គាល់អត់លោកគ្រូ ។

ដារ៉ា ៖ ធ្លាប់ឮឈ្មោះគាត់ធ្វើទាហានឥឡូវ ។

នឿន ៖ ដឹងនៅខាងអីឥឡូវ ខ្ញុំបែក ប៉ុនពីមុនគេហៅគេទទួលដូចលោកអ៊ី ឈានៗ ខាងប៉ៃលិនលោកអ៊ី ឈាន ខាងសំឡូតលោកម៉េត ។

ដានី ៖ លោកម៉េតគាត់ខាងកងពល?

នឿន ៖ បាទ! ប៉ុនខ្ញុំផ្នែកខាងពេទ្យ គេខាងនេះផ្សេង យើងផ្នែកៗយើងដឹងរឿងពេទ្យ ។

ដានី ៖ ខាងនោះគេមានកងទ័ព គេមានស៊ីវិល?

នឿន ៖ មានៗ

ដានី ៖ ខាងកងទ័ពស៊ូម៉េត គាត់អ្នកគ្រប់គ្រងកងទ័ព?

នឿន ៖ បាទ!

ដានី ៖ ចុះខាងស៊ីវិល?

នឿន ៖ ខាងស៊ីវិល ហ៎!កាលនឹងដូចជាឈ្មោះអីគ្នាគាត់ ជាផ្នែកៗសំឡូតចែកជា២-៣កន្លែងទៀតបឹងនៅកន្លែងតូចៗ ខ្ញុំកន្លែងពេទ្យតែម្តងនិយាយឲ្យចំ មន្ទីរពេទ្យម៉ាសំឡូតៗ ពេលនោះលោកគ្រូខ្ញុំជម្រាប ខ្ញុំពេទ្យនឹង ខ្ញុំមើលតាំងពីទាហានខ្មែរក្រហម ប្រជាជនខ្មែរក្រហម ប្រជាជនរដ្ឋកម្ពុជា ទាហានរដ្ឋកម្ពុជា ប្រជាជនរដ្ឋកម្ពុជា គាត់ទៅធ្វើត្បូងគាត់ឈឺគាត់អី ខ្ញុំមើលទាំងមិនមានសម្លាប់ទេគេទេ ។

ដានី ៖ នៅបរឡាង?

នឿន ៖ បាទ!ហើយដល់បឹងវៀតណាមមែនទែនទទួលបានទៅដល់ខ្មែរក្រហម គេថាតែចូលខ្មែរក្រហមឬ ខ្មែរក្រហមចាប់បានអន្តរជាតិរត់ទៅក្រៅប្រទេសអស់ទៅ យើងខ្មែរនៅយាមកន្លែងនឹងដែលៗ ខ្ញុំមើលទាំងអស់រហូតដល់បានធ្វើប្អូនថ្ងៃមួយទៀតនៅជាងទង អគ្គក្រឡាញ់ ភូមិអគ្គក្រឡាញ់ ឈ្មោះអីខេម ហៅខេមៗ ស្រុកកំណើតនៅបឹងត្រាញ់ខាងជើង នៅភូមិកូនរមាស ។

ដានី ៖ នៅសំឡូតមានបងប្អូនដែរអត់ នៅសំឡូត?

នឿន ៖ អត់មានទេតែធ្លាក់ៗ ។

ដានី ៖ ដូចបងប្អូនសាច់ញាតិអ្នកស្រុកភូមិជាមួយគ្នា?

នឿន ៖ បាទ! ដូចយើងធ្លាប់ស្គាល់ៗសុំមេ ។

ដានី ៖ គ្នាច្រើនទេ អ្នកដែលថាស្គាល់ៗគ្នានៅស្រុកយើង?

នឿន ៖ ស្គាល់ដែរ លោកគ្រូប៉ុនឥឡូវបែកអស់ អ្នកសំឡូតមកប៉ៃលិន អ្នកប៉ៃលិនមកសំឡូត អ្នកខ្លះមកស្រុក អ្នកខ្លះគេទៅនៅឆ្ងាយៗបែកគ្នាអស់ រកចាំលែងឃើញអស់ហើយ វាដូចហឹអស់ ។

ដារ៉ា ៖ ដូចលោកពូថាមិញ អីរបស់ពូឈ្មោះ ខៀវ នៅ ដែលលោកគ្រូសង្ឃរាជ ធ្លាប់នៅវត្តត្រពាំងធំនឹងទេ?

នឿន ៖ ហ្នឹងនៅនឹង ។

ដារ៉ា ៖ ហើយចុះពីមុនលោកគ្រូសង្ឃរាជ ត្រូវជាអីរបស់ពូ មានលោកគ្រូសង្ឃរាជណាផ្សេងទៀត?

នឿន ៖ មាន ប៉ុនគាត់ស្លាប់បាត់ទៅហើយ ។

ដារ៉ា ៖ ឈ្មោះអីគេ?

នឿន ៖ យើងហៅលោក តាម៉ូវ ស្រុកកំណើតនឹងដែរ តាម៉ូវ មាស ម៉ូវ ។

ដារ៉ា ៖ មាស ម៉ូវ?

នឿន ៖ ស្អី ម៉ូវ ខ្ញុំភ្លេច ។

ដារ៉ា ៖ ចឹងលោកគ្រូសង្ឃរាជមុនអីពូទៀត មុនតានៅទៀត?

នឿន ៖ បាទ!

ដារ៉ា ៖ ឈ្មោះម៉ូវ?

នឿន ៖ តាម៉ូវ គាត់ស្លាប់បាត់ហើយ ខ្ញុំមកអត់ទាន់គាត់ស្លាប់ ។

ដារ៉ា ៖ គ្រូសង្ឃរាជៗពូថាច្រើនណាស់នៅក្នុងភូមិនេះ?

នឿន ៖ បាទ! ច្រើន ។

ដារ៉ា ៖ ដែលគាត់ទៅ?

នឿន ៖ ស្លាប់តៗ ។

ដារ៉ា ៖ មកដល់អីពូឈ្មោះតានៅ?

នឿន ៖ បាទ!

ដារ៉ា ៖ នៅចុងក្រោយ?

នឿន ៖ ក្រោយ ។

ដារ៉ា ៖ ចុះតាម៉ុកអីគាត់សង្ឃរាជដែលនោះ?

នឿន ៖ អានឹងខ្ញុំកើតអត់ទាន់ វគ្គមុនៗ ។

ដានី ៖ ខ្ញុំធ្លាប់អានឯកសារសង្ឃរាជ ដូចថាការមកជួបយាយពូនអី គាត់ថាតាម៉ុកអីគាត់ធ្លាប់បួស?

នឿន ៖ បាទ! ហ្នឹងពីមុន ។

ដានី ៖ បួសនៅនឹងហើយគាត់ផ្លាស់ទៅវត្តមហាមន្ត្រី មានតាម៉ុក តាទិត តាអីណាច្រើន គាត់ថាបួសច្រើននៅជាមួយគ្នា?

នឿន ៖ បើខ្ញុំឃើញៗ យាយពូនកិនម្សៅហ្នឹង ។

ដានី ៖ បាទ! ក្នុងសៀវភៅ?

នឿន ៖ សៀវភៅទស្សនាវដ្ដីនេះនឹងឃើញទេ ។

ដារ៉ា ៖ ឃើញរូបដានី?

នឿន ៖ បាទ! ខ្ញុំមើលឃើញសៀវភៅសុំគេមកមើល ។

ដារ៉ា ៖ ចុះតាទិត តាម៉ុកអី នៅស្រុករជាមួយតានៅដែរ?

នឿន ៖ បាទ! គាត់អ្នកនៅស្រុករៗគ្នាគាត់ ប៉ុនគ្រាន់ថាគាត់ទៅរៀនៗបានបួសចឹងហើយទៅ គាត់ទៅរៀនបាន ពីដើមយើងនិយមបួសហើយទៅរៀន ហើយខ្ញុំក្ដាប់មិនបាន បើខ្ញុំតូចៗពេលខ្លះខ្ញុំមិនទាន់កើតផង រឿងតាម៉ុករឿងគាត់បួសរឿងគាត់ផ្សេងមិនអាចខ្ញុំនិយាយកើតៗអាកន្លែងណាដែលយើងដឹង អ៊ីដែលលើសពីការដឹងយើងនិយាយអត់ពិតប្រាកដ អានឹងហាក់បីដូចជាយើងមិនច្បាស់ ។

ដារ៉ា ៖ យាយពូន គាត់មានប្អូនគាត់យាយគេន?

នឿន ៖ នៅសំឡូតនោះ ។

ដារ៉ា ៖ យាយគេនហ្នឹង?

នឿន ៖ បាទ!

ដារ៉ា ៖ ហើយគាត់ធ្វើបុណ្យធ្វើទាន មកនេះ?

នឿន ៖ មកៗជុំគ្នា ។

ដារ៉ា ៖ ខស្រាប់មកដែរ?

នឿន ៖ បាទ!

ដានី ៖ កាលនឹងពូស្គាល់គាត់អត់ កាលពូទៅសំឡូត?

នឿន ៖ គ្រាន់បានម៉ាស្គាល់ ប៉ុនអត់ដែលបាននៅជាមួយគាត់ ។

ដានី ៖ ខ្ញុំអានឯកសារគាត់ធ្វើពេទ្យដែរ កាលនឹងគាត់នៅគិរីវង់?

នឿន ៖ អូ! កាលនឹងជំនាន់យើង ជំនាន់៣ឆ្នាំ ។

ដានី ៖ ៣ឆ្នាំគាត់ធ្វើពេទ្យ គាត់ទៅនៅសំឡូតគាត់មានធ្វើពេទ្យទៀតទេ?

នឿន ៖ អត់ទេ គាត់ឈប់ធ្វើ កាលគាត់ធ្វើនៅនឹងបែបជំនាន់ខ្ញុំអត់នៅនឹងដែរ ។

ដារ៉ា ៖ បើពូចេញពីភូមិហើយ?

នឿន ៖ បាទ!

ដានី ៖ ស្មានគាត់ទៅសំឡូតធ្វើពេទ្យនៅអន្លកភាព?

នឿន ៖ ដែលធ្វើនឹង រយៈធ្វើតែពួកខ្ញុំដឹងធ្វើតែពួកខ្ញុំដឹង ដល់ពេលនឹងគាត់អត់មានធ្វើ ។

ដានី ៖ ពូស្គាល់ក្រុមគ្រួសារគាត់ដែរ គាត់អ្នកស្រុកភូមិ?

នឿន ៖ ស្គាល់គ្រាន់ម៉ាស្គាល់ បាននៅបានដឹងចិត្តអត់ទេ អត់ដែលបាននៅជាប់ ដូចថាគាត់នៅគិរីវង់ យើងតាកែវ ហើយខ្ញុំទៅនោះអមលាំង តាំងពោធិ៍ កំពង់ឆ្នាំង កំពង់ស្ពឺ ហើយដល់ទៅលង្វែកទៀត ចេញពីលង្វែកទៅខាងកើតកំពង់សោម ។ ចេញកើតកំពង់សោមទៅសៀមរាប ហើយដល់វិលមកថាសំឡូតមិញនឹង ខ្ញុំនៅគ្រប់កន្លែងចឹង ។

ដារ៉ា ៖ ចុះពេលដែលពូមកនៅភូមិនេះ ហើយគាត់មកធ្វើបុណ្យធ្វើទានអី ពូទៅចូលរួមជាមួយគេ?

នឿន ៖ បាទ! បើគេហៅបុណ្យនៅក្នុងស្រុកភូមិ ។

ដារ៉ា ៖ ពូធ្លាប់ទៅចូលរួមបុណ្យទាន?

នឿន ៖ ខ្ញុំឲ្យប្រពន្ធកូនទៅ តែចូលបុណ្យចូលអីហូបទំហើយ យើងមកវិញមក ។

ដារ៉ា ៖ ចុះគ្រួសារយាយកេនឈ្មោះអី?

នឿន ៖ គ្រួសារយាយកេន តាទិតនឹងហើយ ។

ដារ៉ា ៖ តាទិតនឹងម៉ង?

នឿន ៖ បាទ!

ដារ៉ា ៖ គាត់អ្នកស្រុកភូមិនេះតើ?

នឿន ៖ គាត់នៅស្រុកនេះដែរ ប៉ុនគាត់ស្រុករមុន ។

ដានី ៖ ឪពុកគាត់ឈ្មោះអីទៅ តាទិត?

នឿន ៖ ខ្ញុំកើតអត់ទាន់ ។

ដានី ៖ តែពូចាស់ៗនិយាយ?

នឿន ៖ ពូតែនិយាយ ប៉ុនមិនដឹងឈ្មោះអី ខ្ញុំអត់ចាំដែរ អត់ចាប់អារម្មណ៍និយាយទៅ ។

ដានី ៖ បងប្អូនគាត់ដែរទេ តាទិត យាយកេន?

នឿន ៖ ខ្ញុំអត់ដឹងព្រោះអីខ្ញុំអាយុ១២ ការរាប់ខ្សែស្រឡាយទាល់ចាស់ៗ សូម្បីតែលោកគ្រូក៏ដោយ បើសិនជាដូនតាម៉ាកុងយើងពីមុនយើងពីមុនគាត់ដឹងគ្នាគាត់ ហើយមកដល់ត្រឹមលោកគ្រូអត់រាប់រៀបបានល្អិតទេណា វល់ជាប់រៀនសូត្រអី បែកគ្នាបាត់ ដល់មកខ្ញុំទៀត សង្គ្រាមឡប់ឡិនចេះ ដល់ចឹងអត់បានចាប់អារម្មណ៍ អត់បានល្អិត ។

ដារ៉ា ៖ តែជួនកាលលោកពូនៅវ័យក្មេងជាងចឹង លោកពូបានរៀនបានសូត្រអី ថាចេះអក្សរចេះអី លោកពូអាចសួរនាំចាស់ទុំអី?

នឿន ៖ អត់បាននៅស្រុក ដល់អត់បាននៅបែកៗគ្នា សង្គ្រាមកាលយើងនៅ៣ឆ្នាំ វាអត់បាននៅជុំគ្នា ហើយអាពេលនឹងដែលយើងចង់រួមចង់ស្គាល់ពូជពង្សនឹង ហើយដល់ពេលនឹងវាបែករហូត ទើបយើងចចារសន្និសិទនៅប៉ារីស មកបង្រួបបង្រួមវិញដូចជាវាក់អឺ ដល់ក្មេងក្រោយៗមកវាបាត់វាចេះរាំបទញាក់ ។

ដានី ៖ ចេះរាំបទញាក់ ។

នឿន ៖ បាទ! ហើយអាបទពីដើមវាអត់ចេះ ប្រៀបធៀបចឹងទៅ ។

ដានី ៖ ចុះលោកតាខៀវ នៅ គាត់យ៉ាងម៉េចដែរ ដូចប្រវត្តិគាត់នៅស្រុកភូមិ គាត់បួស គាត់អី?

នឿន ៖ គាត់តែរៀននឹងម៉ង បួសតាំងនៅតូច ។

ដានី ៖ បួសតាំងពីតូច?

នឿន ៖ បាទ! បួសតាំងពីតូច ហើយខ្ញុំទៅបាត់ ដល់ពេលក្រោយមកគេសឹកលោកសឹកអី យូរៗជួបមិនដែលបានជួប ទើបជួបក្រោយនេះមកគាត់ធ្វើអាចារ្យ កាលនៅលោកយើងឃើញកាលនឹងដល់យើងបាត់ៗរហូត ។

ដានី ៖ គាត់សឹកឆ្នាំណា ឆ្នាំចេញពីសង្ឃរាជវត្ត?

នឿន ៖ ឆ្នាំ៧៥ ។

ដានី ៖ ឆ្នាំ៧៥?

នឿន ៖ បាទ! អត់ចាំខែ ក្រោយយើងឈ្នះភ្នំពេញហើយ ខែណាំលោកគ្រូអាខែបួននឹង ។

ដារ៉ា ៖ ពេលពួរត់ចេញពីភូមិនឹង គាត់នៅជាសង្ឃនៅឡើយ?

នឿន ៖ អូ! នៅសង្ឃ នៅបួសជាលោក ធ្វើគ្រូថ្នាំខ្មែរនឹង ដុសមើលប្រជាជន មើលអ្នកស្រុកអ្នកភូមិ

ដានី ៖ ដល់ពេលគាត់សឹកហើយទៅ គាត់ទៅធ្វើអីទៀតទៅ?

នឿន ៖ ដឹងទៅណា បើខ្ញុំអត់ដែលនៅស្រុកផង ។

ដានី ៖ ក្រោយមកគាត់មានប្រពន្ធមានកូន?

នឿន ៖ បាទ! មាន ។

ដានី ៖ ប្រពន្ធគាត់អ្នកស្រុកណា?

នឿន ៖ ប្រពន្ធគាត់នៅតាកែវ នៅបៀត ល្មា លោកគ្រូស្គាល់ផ្សារល្មេៗខាងត្បូងតាកែវ ។

ដារ៉ា ៖ ផ្សារល្មា?

ដានី ៖ ល្មា?

នឿន ៖ ល្មេ ហួសព្រែកសណ្តែតទៅខាងត្បូងតិចមិនល្មេ ។

ដានី ៖ គាត់រៀបការឆ្នាំណា?

នឿន ៖ បាទ!

ដានី ៖ ប្រពន្ធលោក ខៀវ នៅ?

នឿន ៖ ខ្ញុំអត់ដឹងដែរ ស្រាប់តែឃើញមានកូនមានចៅ អត់បានដេញដោលបើបែកបាត់តាំងនៅលោក

ដានី ៖ គាត់ចាស់ហើយបានរៀបការ?

នឿន ៖ បាទ! ចាស់ហើយ ចាស់ ។

ដានី ៖ ប្រពន្ធគាត់ឈ្មោះអីទៅ?

នឿន ៖ ឈ្មោះ ខ្ញុំហៅសំអឿនៗ ប៉ុនមិនដឹងអីអឿន ។

ដានី ៖ សំអឿន?

នឿន ៖ បាទ!

ដានី ៖ គាត់មានកូនចៅច្រើនដែរ?

នឿន ៖ កូន៦នាក់ ។

ដានី ៖ សព្វថ្ងៃនៅអន្លង់វែង?

នឿន ៖ នៅអន្លង់វែង ។

ដានី ៖ ទាំងអស់ ទាំងគ្រួសារគាត់នៅអន្លង់វែង ទាំងអស់?

នឿន ៖ បាទ! ការហើយនៅកោះក្រឡនេះមួយ កូនស្រីមានតែមួយ៦នាក់ ហើយប្រុសមួយនៅកំពង់ចាម មានប្រពន្ធនៅកំពង់ចាម ។

ដានី ៖ នៅអន្លង់វែងនៅម្តុំណា ខ្ញុំខស្បាហ៍ទៅកាលពីមុន?

នឿន ៖ ជិតផ្សារ ខ្ញុំអត់ដែលចូលទៅទេ អន្លង់វែងអត់ដែរទៅ ចេះថាអន្លង់វែងៗ ប៉ុនដឹង ។

ដានី ៖ អត់ដែលទៅ?

នឿន ៖ បាទ! អត់ដែលទៅ ដឹងត្រឹមណាត្រឹមណោ ។

ដានី ៖ គាត់មានដែលមកលេង?

នឿន ៖ គាត់លើកមុនគាត់មកដែរ ប៉ុនគាត់មកចឹងគាត់ទៅវត្តសូត្រធម៌ជាមួយតាៗចាស់ អាយើងក្មេងៗក្រោយៗវាខុតស៊េរីគាត់ ។

ដានី ៖ គាត់នៅអន្លង់វែង គាត់ធ្វើអាចារ្យដែរ?

នឿន ៖ អាចារ្យ គាត់មិនដែលបានសម្លាប់អាណាមួយទេ ធ្វើតែលោក ធ្វើអាចារ្យ ។

ដានី ៖ គាត់ធ្វើតែអាចារ្យ ស៊េរីគាត់ដូច... ។

ដារ៉ា ៖ ដូចតាទិតអាចារ្យដែរតើ?

នឿន ៖ បាទ! គាត់អត់ពេញចិត្តរឿងកុម្មុយនីសទេ ប៉ុនគេចមិនរួច ក្នុងរបបថ្ងៃរះមកវាតែងតែចឹងយើងនៅក្នុងនឹងដែរ ។

ដានី ៖ មិត្តភ័ក្តរបស់គាត់ហើយម៉េច តានៅ តាទិត តាម៉ុកអីនឹង?

ដារ៉ា ៖ សុទ្ធស៊េរីអាចារ្យៗ ?

នឿន ៖ ស៊េរីគ្នាគាត់ អ្នកបួសរៀនមិនដឹងយ៉ាងម៉េចលោកគ្រូ ខ្ញុំវាក្តាប់អត់បាន ក្តាប់អត់បាន ដូចស៊េរីមុនរាំបទស្លូ រាំបទរាំវង់ ដល់ឥឡូវច្រើនបទញាក់ ខ្ញុំប្រៀបធៀបចឹង ក្មេងៗក្រោយដូចថាអត់ដឹងរឿងគាត់ ។

ដារ៉ា ៖ ពូដែលៗពុគេហៅតាទិតៗ ដែលពុគាត់មានឈ្មោះអី ដើមយ៉ាងម៉េច?

នឿន ៖ អត់ទេ អត់ដែលបានសួរផង ។

ដានី ៖ ដូចតានៅ គាត់ឈ្មោះ ខៀវ នៅ តាម៉ុកគាត់?

នឿន ៖ ខ្ញុំអត់ដែលបាននេះផង ព្រោះគាត់បួស គាត់រៀនមិនដែលសូវឃើញមុខ ហើយដល់ពេលយើងក្រោយមករដ្ឋប្រហារ ខ្ញុំដូចជម្រាបលោកគ្រូខាងដើម ក៏ទៅបាត់ទៅ ។

ដារ៉ា ៖ តែពេលគាត់ចូលមកភូមិវិញ ចូលមកធ្វើបុណ្យធ្វើទាន?

នឿន ៖ មកចឹងទៅ គាត់ជុំគ្នាគាត់សូត្រធម៌ចឹងទៅ ហើយខ្ញុំឲ្យប្រពន្ធកូនទៅបុណ្យ ហូបចូលបុណ្យហូបនំហើយមកផ្ទះវិញមក ចប់បុណ្យចប់រឿងក្រុមគ្រួសារដែលបូកគ្នាដែលធ្វើបុណ្យនឹងទៅ យើងមិនបានក្តាប់មិនបានដេញដោល ចុះអាការផ្សារប្រញាប់កូនរៀនសូត្រចឹង អត់មានអ្នកនៅផ្ទះប្រញាប់មក ។

ដារ៉ា ៖ ហើយពេលមកបុណ្យទាន ពូមានថតរូបថតអីជាមួយគ្នា?

នឿន ៖ អត់ៗដែរ ខ្ញុំអត់ដែលបានទៅកន្លែងបុណ្យនឹងទៀត តែប្រពន្ធកូនខ្ញុំទៅទេ ។

ដារ៉ា ៖ ចឹងអាចសុំស្លួរមីងបាន?

នឿន ៖ មីងនឹងទៅចូលតែបុណ្យ ។

ដានី ៖ មីងស្គាល់តាទិតទេ មីង?

នឿន ៖ គ្រាន់ស្គាល់ចូលបុណ្យចូលអីនឹង ។

ប្រពន្ធ ៖ អត់ដែលស្គាល់ផង ធ្លាប់ឮឈ្មោះនឹង ប៉ុនមិនដឹងស្រុកកំណើតនៅណា ។

នឿន ៖ គាត់នៅជាងទង ។

ដារ៉ា ៖ នៅជាងទង?

នឿន ៖ បាទ! ដូចថាប្រាប់បុណ្យនឹង ឧទាហរណ៍ថាមានពិធីបុណ្យចូលបុណ្យហើយហូបនំចូលមកវិញមក គេអ្នកទៅក្រោយចូលលើគេ កូនទៅរៀនអស់អត់អ្នកណានៅផ្ទះ ប្រញាប់ ខ្ញុំនៅចាំផ្ទះពេលវល់ដឹណាំដំនោចគោ ហូបហើយបានមកវិញមក ។ មកដល់ពេលវេលានឹងហើយ អស់សូវបាននៅយូរ ។

ប្រពន្ធ ៖ ដល់ម៉ោងបានទៅ ។

នឿន ៖ ជួនកាលបុណ្យ២កន្លែងចឹង បុណ្យហើយទៅនោះ ។

ដារ៉ា ៖ ចុះកាលបុណ្យសពយាយពូននោះ គាត់មកដែរ យាយគេនៗគាត់មកដែរ?

នឿន ៖ មកដែរ បាទ!ពេលដុំៗគ្នាខ្ញុំមិនដែលបានទៅជិត ដល់ពេលចូលបុណ្យបានមក ។

ដានី ៖ យាយពូនគាត់មកបងប្អូនច្រើនដែរ?

នឿន ៖ បងប្អូនគាត់ មិនដឹងប៉ុន្មាននាក់យាយ ។

ដានី ៖ ចុងក្រោយខ្ញុំចង់ស្គាល់ឈ្មោះពូពេញ មិញអត់បានសួរឈ្មោះពូ ឮឈ្មោះពេទ្យនឿនៗ ។ ពូឈ្មោះពេញ ឈ្មោះអីទៅ?

នឿន ៖ ខ្ញុំឈ្មោះ ងឹម នឿន ។

ដានី ៖ ងឹម នឿន?

នឿន ៖ បាទ! ងឹម នឿន ។

ដានី ៖ ពូសព្វថ្ងៃអាយុប៉ុន្មានហើយ?

នឿន ៖ ខ្ញុំអាយុ៥០ជាងហើយ ។

ដានី ៖ ៥០ប៉ុន្មាន?

នឿន ៖ ៥២ហើយ ។

ដានី ៖ ៥២ន៎ះពូ ។ ស្រុកកំណើតកើតជានៅភូមិឃុំស្រុកអីដែរ?

នឿន ៖ ភូមិត្រពាំងឈូក ឃុំត្រពាំងធំខាងត្បូង ស្រុកត្រាំកក់ ខេត្តតាកែវ ។

ដានី ៖ សព្វថ្ងៃនៅភូមិនឹងដែរ?

នឿន ៖ បាទ! ប៉ុន្តែនៅខុសភូមិកំណើត ។

ដានី ៖ ចុះមីង?

ប្រពន្ធ ៖ ខ្ញុំនៅជាផងទផង ។

នឿន ៖ គាត់នៅជាផងទផង ។

ដានី ៖ ភូមិអីគេ?

ប្រពន្ធ ៖ អន្លក់ក្បឺ ជាផងទផង ។

ដានី ៖ ភូមិអីគេ?

ប្រពន្ធ ៖ អន្លក់ក្បឺ ឃុំជាផងទផង ។

ដារ៉ា ៖ អន្លក់ក្បឺ ជាផងទផង ។

ដានី ៖ មីងឈ្មោះអីដែរ ឈ្មោះពេញ?

នឿន ៖ ទូច សារី ។

ដារ៉ា ៖ ទូច សារី អន្លក់ក្បឺ ។

ដានី ៖ មីងអាយុប៉ុន្មានហើយសព្វថ្ងៃ?

ប្រពន្ធ ៖ ច្រើនហើយ ។

នឿន ៖ ៥០

ដានី ៖ បាទ?

ប្រពន្ធ ៖ ៥០ ។

ដានី ៖ ៥០គត់?

នឿន ៖ បាទ!

ដារ៉ា ៖ ប្អូនពូតែ២ឆ្នាំ ។

ដានី ៖ កូនចៅប៉ុន្មាននាក់ទាំងអស់?

នឿន ៖ កូនចៅនៅតែ៤ ប្រុស២ ស្រី២ ។

ដានី ៖ ប្រុស២ ស្រី២?

នឿន ៖ បាទ!

ដារ៉ា ៖ ពួកប្រុសៗនោះបានទៅរៀនមុន?

នឿន ៖ បាទ!

ដារ៉ា ៖ ព្រោះវាចប់មុន?

នឿន ៖ ចប់មុន ។

ដានី ៖ ឪពុកពូឈ្មោះអី?

នឿន ៖ ពុកម៉ែខ្ញុំគាត់ស្លាប់អស់ហើយ ។

ដានី ៖ បាទ! គាត់ឈ្មោះអីទៅ?

នឿន ៖ ទាម នូ ឪពុក ។

ដារ៉ា ៖ ទាម នូ ឪពុក?

នឿន ៖ បាទ!

ដារ៉ា ៖ ចុះពូដាក់ត្រកូលអត់ដូច?

នឿន ៖ ខ្ញុំឪៗតានូ ។

ដារ៉ា ៖ ឪតានូនឹងទៀត?

ដានី ៖ ទាន នូ គាត់ស្លាប់យូរហើយ?

នឿន ៖ បាទ!

ដានី ៖ ស្លាប់តាំងពីអន្លក់?

នឿន ៖ ស្លាប់កាលយើងបោះឆ្នោតហើយ ខ្ញុំមកទាន់គាត់ដែរ បានថែគាត់ដែរ ។ ហ៎! បោះឆ្នោតហើយបានម៉ាឆ្នាំ ។

ដារ៉ា ៖ ៩៨ហើយចឹង?

នឿន ៖ បាទ! ៩៨ ខ្ញុំអត់ចាំថ្ងៃ កត់ទុកហើយបាត់សៀវភៅ ។

ដានី ៖ ចុះម្ដាយ?

នឿន ៖ ម្ដាយដឹងនេះអីទេ ហៅយាយឡាងៗ ។

ដារ៉ា ៖ អូ! យាយឡាង ។

ដានី ៖ យាយឡាង ។

នឿន ៖ ប៉ុនខ្ញុំដាក់ត្រកូលខាងឪគិតគូអី ។

ដានី ៖ គាត់ស្លាប់ពីអន្លក់ដែរ?

នឿន ៖ ម៉ែស្លាប់កាលយើងចេញចូលព្រំដែន កាលនឹង ការដឹកជញ្ជូនជនមាតុភូមិនិវត្តន៍តិចតួច ដំបូងកាលនឹង៩០ប៉ុន្មាន ៩១ ។

ដារ៉ា ៖ ៩១?

ដានី ៖ ៩១, ៩២?

នឿន ៖ បាទ!

ដារ៉ា ៖ ដែលគាត់ខូចនៅស្រុកភូមិនេះ?

នឿន ៖ បាទ! បកមកស្រុកវិញ គាត់ឈឺគ្រុនចាញ់ ។

ដារ៉ា ៖ គាត់បកមកនឹងដែរ?

នឿន ៖ បាទ! អត់ទេ គាត់មកលេង ដើររកកូន ប៉ុន្តែអត់ជួប ។

ដារ៉ា ៖ អត់ជួបទេ?

នឿន ៖ អត់ដែលជួបទេ ។

ដានី ៖ គាត់ទៅដល់សំឡូតដែរ?

នឿន ៖ ដល់ជាមួយអ្នកដែលទៅនឹង គេថានៅត្រង់នេះនៅត្រង់នោះ ឯងកុំទៅកន្លែងនឹងប្រយ័ត្នឈឺ ងាប់ គាត់ខ្លាចគាត់ទៅផ្ទះវិញ ។ មកដល់គាត់ឈឺស្លាប់ ។

ដារ៉ា ៖ ដែលឈឺស្លាប់ដោយសារទៅរកពូ?

នឿន ៖ បាទ! ដើរទៅរកខ្ញុំ ខ្ញុំខ្ជិលនេះដល់ចឹងខ្ញុំមកផ្ទះវិញ ។

ដារ៉ា ៖ និយាយទៅ នៅក្នុងគ្រួសាររបស់ឪពុកម្ដាយរបស់ពូមានបួនតែ២នាក់ ពូថាមានបួនពៅមួយ នោះ?

នឿន ៖ បាទ! ៦នាក់ស្លាប់រត់៧៩ ស្លាប់ខ្ញុំអត់បានដឹង ស្លាប់ជាមួយយាយនៅលើភ្នំខ្ពស់ ។

ដារ៉ា ៖ ចឹងមានន័យថាគាត់នៅសល់កូនតិច បានគាត់ខំដើររកពូ?

នឿន ៖ បាទ! កូនដែលនៅជាប់នឹងគាត់នឹង កើត៧៦មួយ នឹងកើតឆ្នាំ៨០មួយ តែ២នាក់ ដល់ចឹង គាត់បាត់បង់បង១គាត់នឹកឃើញអាណិតស្រឡាញ់កូន១គាត់ ។

ដានី ៖ គាត់បងប្អូនប៉ុន្មាននាក់ ម្ដាយ?

នឿន ៖ មិនដឹងប៉ុន្មាន ស្លាប់បាត់អស់ កើតអត់ទាន់ផង ។

ដានី ៖ មានអ្នកនៅរស់ដែរ?

នឿន ៖ អត់ទេ ស្លាប់អស់ ដល់កើតអត់ទាន់ អត់បានចាប់អារម្មណ៍ពួ១តែគាត់ថា ។

ដានី ៖ ចឹងឪពុកពូគាត់មានបងប្អូនប៉ុន្មាននាក់?

នឿន ៖ ឪពុកខ្ញុំស្រុកកំណើតនៅឃុំគូសទៀត រាល់ថ្ងៃនឹងនៅតែអ៊ីមួយទេ ហើយមុន១មិនដឹងប៉ុន្មាន នាក់ទៀត វាបាត់ស្លាប់អស់ បាត់អស់ វាអត់ដែលនៅស្រុក ។

ដានី ៖ ពូបងប្អូនបង្កើតប៉ុន្មាននាក់?

នឿន ៖ ខ្ញុំ៦នាក់ ស្លាប់មួយនៅសល់៥ ។

ដានី ៖ ស្រីប៉ុន្មានប្រុសប៉ុន្មាន?

នឿន ៖ ប្រុស២ ស្រី៣ ។

ដានី ៖ ពូកូនទីប៉ុន្មាន?

នឿន ៖ ខ្ញុំបងគេបង្អស់ ។

ដានី ៖ ភាគច្រើនដូចថាពូធ្លាប់ទៅតស៊ូ ភាគច្រើនគេនៅតាមទល់ដែន គេនៅខាងសំឡូត នៅខាងម៉ាឡៃ ខាងអីនឹង អត់សូវច្រើនមកស្រុកកំណើតទេ?

នឿន ៖ បាទ! គេនៅនឹង គេចាប់ដី ចាប់ធ្លីនៅ ធ្វើជាចំការ ធ្វើជាមូលដ្ឋានរបស់គេទៅ ។

ដានី ៖ ខ្ញុំធ្លាប់ទៅខាងអន្លង់វែង ទៅខាងម៉ាឡៃ ខាងសំឡូត?

នឿន ៖ អូ! ម៉ាដូរម៉ាឡៃឥឡូវអស់ទាស់ហើយ គេកសាងមូលដ្ឋានធំៗ និយាយរួមផ្ទះធំៗ ។

ដានី ៖ បាទ! ដូចថាមានដីមានអីច្រើន ហើយគ្រួសារគេដូចធូរធារដែរ ភាគច្រើន

នឿន ៖ បាទ! កន្លែងនឹងធូរ ព្រោះគេខាងចំការដំឡូង ។

ដានី ៖ កាលនឹងពូទៅកាលនឹងទៅនៅសំឡូត ពូម៉េចត្រឡប់មកវិញ?

នឿន ៖ នឹកថាម្ដាយថារឿងម្ដាយពុស្ញូវតែដើររកកូនពេក ដើរអត់ដែលដល់កន្លែងខ្ញុំនៅ ក្រោយមកពុថាស្លាប់ ខ្ញុំសុំចូលជំរំ ។

ដានី ៖ ដូចអ្នកនៅសំឡូត ដូចពូមានប្រសាសន៍មិញថាមានអ្នកស្រុកអ្នកភូមិស្គាល់គ្នាច្រើនដែរ ពួកគាត់មកវិញទាំងអស់ ហើយក៏ពួកគាត់នៅនឹង?

នឿន ៖ គេនៅនឹង ។

ដានី ៖ គេនៅសំឡូត មកតែពូម្នាក់ឯង? ពីណាខ្លះទៅអ្នកនៅនឹង?

នឿន ៖ អ្នកស្គាល់ៗគ្នា ដូចខ្ញុំនិយាយថា ។

ដានី ៖ អ្នកភូមិយើង?

នឿន ៖ បាទ!

ដានី ៖ ពីណាគេខ្លះទៅ អាចពេលខ្ញុំទៅសំឡូតទៅជួបពួកគាត់សួរនាំរឿងរ៉ាវដូចពូដែរ?

នឿន ៖ ឈ្មោះ ពឿនមួយ ប៉ុនមិនដឹងនៅចំកន្លែងណា គេហៅអូររថក្រោះៗសំឡូតនឹងពីខាងលិចសាលាស្រុក ។

ដានី ៖ ខាងលិចសាលាស្រុក ឈ្មោះពឿន?

នឿន ៖ បាទ! ឈ្មោះពឿនប្រុស ។

ដានី ៖ ប្រពន្ធគាត់ឈ្មោះអី ក្រែងលខ្ញុំទៅលេង?

នឿន ៖ ឈ្មោះពៅ ។

ដានី ៖ ថាមកជួបពូ?

នឿន ៖ ប៉ុនអត់ដឹងត្រកូល ដឹងយើងហៅ ។

ដានី ៖ បាទ! ពឿន, ពៅ ទៅដល់កន្លែងអូររថក្រោះសួរគេនេះ?

នឿន ៖ បាទ!

ដានី ៖ អ្នកណាទៀតទៅ ក្រែងលខ្ញុំទៅ ខ្ញុំទៅជួបពូទៅលេងជួបគាត់ សួរនាំពីជីវិតគាត់?

នឿន ៖ បែកយូរវាពិបាកអ្នកខ្លះខេត្តឆ្ងាយរកនឹកលែងឃើញអស់ ។

ដានី ៖ ដូចថាអ្នកនៅស្រុកជាមួយពូនេះ អ្នកដូចថាស្គាល់ៗពូនៅស្រុកនឹង ហើយទៅនៅសំឡូតជាមួយគ្នា?

នឿន ៖ ខ្លះគេមកប៉ៃលិនវិញ ត្រឡប់ត្រឡិនៗ ។

ដានី ៖ ក្រែងលខ្ញុំទៅសំឡូត ទៅប៉ៃលិនទៅអី ព្រោះអីពូកខ្ញុំដើរធ្វើការគ្រប់តាមខេត្តផ្សេងៗច្រើនដែរ នេះនៅសំឡូត នៅអូររថក្រោះ ។

នឿន ៖ នៅប៉ៃលិននៅប្រពន្ធបងរៀប ចៅហ្វាយស្រុក?

ប្រពន្ធ ៖ សុខ ផល ។

ដានី ៖ ផល?

នឿន ៖ បាទ! សុខ ផល ។

ដានី ៖ សុខ ផល?

នឿន ៖ បាទ! ប្ដីឈ្មោះ រៀប ប៉ុនដឹងធ្វើស្រុក ។

ដានី ៖ ប្ដីចៅហ្វាយស្រុក ។ ចៅហ្វាយស្រុកអីគេ?

នឿន ៖ ស្រុកអីគេ ស្រុកប៉ៃលិន ខ្ញុំអត់បានដឹងដែរ ។

ដានី ៖ វាមាន២ស្រុក គឺស្រុកសាលាក្រៅ និងទឹរូមខេត្តតែម្ដង ។

នឿន ៖ គេនៅក្នុងកន្លែង ដែលផលនឹងបាននៅភូមិ ប្ដីគាត់ស្រុកកំណើតនៅកំពង់សិលា បងរៀបដូចចៅហ្វាយស្រុកនៅក្នុងក្រុងដែរប៉ុនយើងមិនបានល្អិតល្អន់ការងារ ពេលគាត់ធ្វើបុណ្យធ្វើអីជួបម៉ាភ្លែតៗ ។

ដានី ៖ ២នាក់នឹងទេ មានពីណាផ្សេងទៀតទេ ឲ្យច្រើនតិចទៅក្រែងលខ្ញុំទៅអត់ជួបគាត់ ជួបអ្នកផ្សេងអីចឹង?

នឿន ៖ ដឹងត្រង់ណាលោកគ្រូ បែកអស់ វាលែងច្បាស់ហើយឥឡូវដឹងត្រឹមច្បាស់ ។

ដានី ៖ បាទៗ ចឹងខ្ញុំអរគុណច្រើនលោកពូ ។

«ចប់»